Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៩០

## របស់ប្លាស្ទិក កំប៉ិកកំប៉ុក តែ មានឥទ្ធិពល ដល់ជីវិត



អម៉ាណូអែល
"សម្លេងផ្សាយពីព្រះសហគមន៍កាតូលិក"

ភ្នំពេញ : FM 104 Mhz ម៉ោង ៥:០០- ៦:០០ រសៀល
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០- ៨:៣០ យប់
សៀមរាប : FM 107.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
កំពង់ធំ : FM 103.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
ព្រះសីហនុ : FM 92.5 Mhz ម៉ោង ៥:០០- ៦:០០ រសៀល
កំពត : FM 93.25 Mhz ម៉ោង ៥:០០- ៦:០០ រសៀល

កម្មវិធីវិទ្យុសម្រាប់យុវជន
ខ្ញុំត្រូវការអ្នក
ផ្សាយតាមរលកធាតុអាកាស
FM 99.5Mhz រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០-១១:០០ព្រឹក

# រូបថតសកម្មភាពផ្សេងៗ



? ? ? ? ? ? ? ? ? ? ? ? ?



លោកអភិបាល គីគេ ធ្វើពិធីសម្ពោធមជ្ឈ-មណ្ឌលសិក្សារបស់ព្រះសហគមន៍កាតូលិកបាត់ដំបងរបស់ក្រុម គ្រួសារបងស្រី ឧសុលិន នៅព្រះសហគមន៍ច្រាបវាល។




ការអប់រំអំពីរបៀបសមាធិដកដង្ហើមចេញចូលឲ្យមានអារម្មណ៍ស្ងប់ដោយលោកពុកតូតេត។




អភិបូជាសម្រាប់បេក្ខនារីពីរនាក់ ដែលត្រៀមចូលបួស នៃក្រុមស្រលាញ់ព្រះឈើឆ្កាងឆ្នាំទី១ គឺ ពេន ហ៊ីល និង រដ្ឋា នៅភូមិភាគកំពង់ចាម ចូលរួមពីលោកអភិបាលអនតូនី សាមីស៊ូសៃរាជ។



ដំណើរកំសាន្តរបស់បុគ្គលិក និងសិស្សវិទ្យាល័យសន្ត ហ្វ្រង់ស័រដែលមានចំនួនសរុបប្រហែល៧០នាក់ កាលពីថ្ងៃទី០៧ ខែកញ្ញា ២០១៥។

CSC
Formation, Dialogue, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខៈ ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# កំណែតម្រង់ជួយដល់សិស្សឲ្យមានសម្ថភាពពិតប្រាកដ



*លោក លី សុវណ្ណា*
*ចាងហ្វាងកាសែតអ្នកនាំសារ*

លទ្ធផល នៃការប្រលងសញ្ញាប័ត្រទុតិយភូមិ ឆ្នាំ២០១៥ ជាប្រធានបទក្តៅ ដែលគ្រប់គ្នាមានការចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះឃើញយថា មានយុវសិស្ស ដែលមាននិទ្ទេស ល្អប្រសើររហូតដល់ចំនួន១០៨នាក់។

ស្របពេលក្រសួងអប់រំយុវជន និងកីឡាបានធ្វើការកែទម្រង់ស៊ីជម្រៅ លើការប្រលងសញ្ញាប័ត្រទុតិយភូមិ ក្នុងរយៈពេល២ឆ្នាំចុងក្រោយ។ យើងឃើញថា យុវជនដែលចូលរួមប្រលង បានទទួលលទ្ធផលគាប់ចិត្តតិចតួច ក្នុងឆ្នាំ២០១៤ ទាំងការប្រលងលើកទី ១ និង ទី២សិស្សប្រលងជាប់ ចំនួន ៣៣៩៩៧នាក់ (ទទួលបាននិទ្ទេសល្អប្រសើរចំនួន១១នាក់) ក្នុងចំណោមបេក្ខជនសរុបចំនួន ៨៩៩៣៧នាក់ ។ នៅក្នុងឆ្នាំ២០១៥ មានការកើនឡើងសិស្សដែលប្រលងជាប់ មានចំនួន ៤៦៥៦០ នាក់ (សិស្សដែលទទួលនិទ្ទេសល្អប្រសើរចំនួន ១០៨នាក់) ក្នុងចំណោម បេក្ខជនចូលប្រលង ចំនួន ៨៣៣២៥នាក់។ តាមលទ្ធផល បានបញ្ជាក់ថា ការកែទម្រង់របស់ក្រសួងអប់រំកំពុងចំរាញ់យកបេក្ខជន ដែលមានសមត្ថភាពពិតប្រាកដ ក្រោមពាក្យស្លោក "អ្នកចេះគឺជាប់"។ ទាំងនេះយើងពិតជាចូលរួមអបអរសាទរ ព្រោះថា កម្ពុជាត្រូវការធនធានមនុស្សពិតប្រាកដ ដើម្បីអភិវឌ្ឍប្រទេស ឲ្យប្រសើរឡើងនាពេលអនាគត។ ដោយសារកន្លងមក មានពាក្យជាច្រើន បានរិះគន់ប្រព័ន្ធអប់រំយ៉ាងខ្លាំង ថាមានកម្រិតទាបមានសិស្សថ្នាក់ទី ១២ ជាច្រើនបានប្រលងជាប់តែគ្មានគុណភាព។ កំណែទម្រង់មួយនេះ បានលប់បំបាត់ពាក្យ រិះគន់ទាំងនេះ បានតែបែរជាមានពាក្យថា កំណែទម្រង់មានភាពរហ័សពេកទៅវិញ កាលពីឆ្នាំ២០១៤។ ទោះជាយ៉ាងណា លោករដ្ឋមន្ត្រីក្រសួងអប់រំ បានយកចិត្តទុកបន្តកិច្ចការនេះ។

កំណែទម្រង់ជំរុញឲ្យសិស្សានុសិស្សថ្នាក់ទី១២ កាន់តែខិតខំថែមទៀត។ តើប្អូនៗដែលនឹងចូលរៀនថ្នាក់ ទី១២ ក្នុងឆ្នាំសិក្សា ២០១៥-២០១៦ បានត្រៀមខ្លួនហើយឬនៅ? កម្មវិធីអប់រំសម្រាប់ពួកគេ មានលក្ខណៈគ្រប់គ្រាន់ឬនៅ? តើយុវសិស្សគួរនៅតែបន្តទៅរៀនគួរទៀតឬយ៉ាងណា? ឬយកពេលច្រើន ដើម្បីអានសៀវភៅ ស្រាវជ្រាវឲ្យបានច្រើន? តើរៀនដើម្បីជាប់ ឬរៀនដើម្បីចេះ?

ការកែទម្រង់នេះ ជាសញ្ញាជួងមួយឮសូរយ៉ាងខ្លាំង ដាស់ស្មារតីដល់យុវសិស្សមួយចំនួន ដែលមិនយកចិត្តទុកដាក់នឹងការរៀនសូត្រ អាងលុយទិញពិន្ទុឲ្យបានជាប់ក្នុងថ្នាក់ និង ឈប់អនុវត្តជាដើម ព្រោះខ្លួនមិនបានចូលរៀន ឬអាងប្រមូលលុយជូនអនុរក្សដើម្បីបានលួចចម្លងជាដើមនោះឲ្យភ្ញាក់ឡើង។

រាជរដ្ឋាភិបាលនៅក្នុងអណត្តិទី ៥នេះ បានខិតខំយ៉ាងច្រើន ក្នុងការកែទម្រង់នូវចំណុចជាច្រើនដែលអសកម្ម។ ការប្រឆាំងអំពើពុករលួយ ជាចំណុចដែលជំរុញការកែទម្រង់ ប្រកបដោយប្រសិទ្ធភាព។ មានមន្ត្រីមានមួយចំនួន ដែលប្រព្រឹត្តអំពើពុករលួយ ត្រូវបានដាក់ទោស និងជាប់ពន្ធនាគារ។

កំណែទម្រង់ត្រូវការ ការចូលរួមទាំងអស់គ្នា ទាំងរដ្ឋ ទាំងពលរដ្ឋ ស្ថាប័នឯកជននានា ជាពិសេសគឺការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ។ មានស្ថាប័នរដ្ឋជាច្រើនដែលប្រកាសកែទម្រង់ចំណុចអសកម្ម តែអនុវត្តមិនទាន់បាន។

នៅអនាគតដ៏ខ្លីខាងមុខ សមាគមប្រជាជាតិអាស៊ាន នឹងធ្វើសមាហរណកម្មសេដ្ឋកិច្ចវប្បធម៌ជាមួយគ្នា។ ពេលនោះអ្វីៗ ត្រូវការប្រកួតប្រជែងជាមួយប្រទេសដទៃ ដែលជាសមាជិកអាស៊ានដូចគ្នា ដូច្នេះកម្ពុជាត្រូវរៀបចំខ្លួន ឲ្យបានរួចជាស្រេច។

សរុបមក យើងសូមចូលរួមអបអរសាទរ យុវសិស្សដែលបានប្រលងជាប់និទ្ទេសល្អប្រសើរ និងយុវសិស្សផ្សេងទៀតដែលបានប្រលងជាប់ ព្រមទាំងសូមអបអរសាទរ ដល់ក្រសួងអប់រំយុវជន និងកីឡា ដែលបានខិតខំកែទម្រង់ ឲ្យការប្រលងប្រកបដោយគុណភាព។ កំណែទម្រង់នេះ ជាគំរូសម្រាប់ស្ថាប័នរដ្ឋផ្សេងៗទៀតដែរ។ សិស្សានុសិស្ស ត្រូវកែរបៀបគិតរបស់ខ្លួន កុំអាងទឹកប្រាក់ អាងខ្នង។ល។ ព្រោះការប្រលងមានតែខ្លួនម្នាក់ ជាអ្នកសម្រេចវាសនារបស់ខ្លួន "អ្នកចេះគឺជាប់" ។ សូមចូលរួម ទាំងអស់គ្នា ទាំងលោកគ្រូអ្នកគ្រូ អាណាព្យាបាល និងសិស្សានុសិស្សផ្ទាល់ខ្លួន ដើម្បីឲ្យកំនែទម្រង់នេះមាននិរន្តរភាពតទៅ។ អនាគតយុវជនកម្ពុជា នឹងមានសមត្ថភាពពិតប្រាកដក្នុងការប្រកួតប្រជែង និងកម្ពុជាក៏នឹងមានធនធានមនុស្សល្អៗ ក្នុងការអភិវឌ្ឍន៍ប្រទេសឲ្យរីកចម្រើន ក្នុងសន្តិភាពដែលមានស្រាប់នេះ៕





*កម្មករ-ការិនីកំពុងធ្វើការនៅក្នុងរោងចក្រនៅបាត់ដំបង។ រូបថតៈ កញ្ញា*

# ត្រួសៗពីសេដ្ឋកិច្ចនៅឆមាសទីមួយដើមឆ្នាំអំឡុងពេលស្ថានភាពនយោបាយនៅនឹងនរ

ស្ថានភាពពាណិជ្ជកម្មកម្ពុជា នៅក្នុងរយៈពេល ពេញមួយឆមាសទីមួយ ដើមឆ្នាំ២០១៥ ខណៈប្រទេសមានស្ថានភាព និងបរិយាកាសនឹងនរ គឺស្ថិតនៅលើផ្លូវវិជ្ជមាន ប្រកបដោយសុទិដ្ឋិនិយម។

បើទោះបីជាកម្ពុជា នៅតែមានឱនភាពពាណិជ្ជកម្មក៏ដោយចុះ ប៉ុន្តែគ្រប់វិស័យសំខាន់ៗគឺសុទ្ធតែមានកំណើន។ មិនតែប៉ុណ្ណោះ កម្ពុជាក៏អាចមានសមត្ថភាព នៅក្នុងការកាត់បន្ថយពំនាក់នាំចេញពី ផលិតផលឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ បានមួយកំរិតថែមទៀតផងដែរ។

ស្ថិតិពីក្រសួងពាណិជ្ជកម្ម បានឲ្យដឹងថា ទំហំពាណិជ្ជកម្មសរុបរបស់កម្ពុជា ជាមួយនឹងបណ្ដាប្រទេសដៃគូទាំងអស់ នៅក្នុងរង្វង់ឆមាសទីមួយដើមឆ្នាំ២០១៥នេះ គឺមានតម្លៃសរុបប្រមាណជា ៩,៧៥ ពាន់លានដុល្លារ ពេលគឺមានកំណើនកើនឡើងប្រមាណ ៩,៥ ភាគរយ ធៀបនឹងទំហំពាណិជ្ជកម្មកាលពីរយៈពេលដដែល កាលពីឆ្នាំ២០១៤ ដែលមានតម្លៃត្រឹមតែ ៨,៩ ពាន់លានដុល្លារ ។

នៅក្នុងរយៈពេល ពីខែមករា ដល់ខែមិថុនា កម្ពុជាបាននាំចេញផលិតផលសរុបប្រមាណជា ៤,១៣ ពាន់លានដុល្លារ ពេលគឺមានកំណើនកើនឡើងប្រមាណជា ៩,៥ ភាគរយ ធៀបនឹង ៣,៧៧ ពាន់លានដុល្លារ នៅក្នុងរយៈពេលដដែលកាលពីឆ្នាំទៅ។ ចំពោះការនាំចូលវិញ គឺនៅតែមានទំហំធំជាងការនាំចេញ ប៉ុន្តែតួលេខស្ថិតនៅក្នុងលំនឹងមួយ ដែលប្រទេសកម្ពុជាអាចនឹងជានាលំនឹង នៃសេដ្ឋកិច្ចបាន។ នៅឆមាសទីមួយ ដើមឆ្នាំ២០១៥នេះ ទំហំនៃការនាំចូលរបស់កម្ពុជា គឺមានទឹកប្រាក់ហូតដល់ទៅ ៥,៦២ ពាន់លានដុល្លារ ពេលគឺមានកំណើនកើនឡើងប្រមាណជា ៨,៥ ភាគរយធៀបនឹង ៥,១៨ ពាន់លានដុល្លារ នៅក្នុងរយៈពេលដដែលកាលពីឆ្នាំ២០១៤ ។

នៅក្នុងចំណោម ផលិតផលនាំចេញសរុបរបស់កម្ពុជា ផលិតផលដែលជាស្នូល និងជាមូលដ្ឋានចំបងនៃពាណិជ្ជកម្មជាតិ គឺនៅតែមានសភាពកើនឡើងស្រួចស្រាលនៅឆមាសទីមួយ ដើមឆ្នាំនេះ។

ការនាំចេញឧស្សាហកម្ម កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង គឺមានកំណើនកើនឡើងប្រមាណជា ៩ ភាគរយផងដែរ នៅឆមាសទីមួយដើមឆ្នាំ២០១៥។ តម្លៃនៃការនាំចេញផលិតទាំងនេះ នៅឆមាសមាសទីមួយដើមឆ្នាំ គឺមានតម្លៃសរុប ៣ពាន់លានដុល្លារ ខណៈដែលកាលពីឆមាសទីមួយឆ្នាំទៅ គឺមានតម្លៃត្រឹមតែ ២,៧៤ ពាន់លានដុល្លារ ។

សញ្ញានៃភាពវិជ្ជមាន នៃវិស័យពាណិជ្ជកម្មរបស់កម្ពុជា នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១៥នេះ គឺភាពវិជ្ជមាននៃការអនុវត្តនយោបាយ ពិពិធកម្មទំនិញ ឬផលិតផលនាំចេញរបស់កម្ពុជា ពេលគឺភាពជោគជ័យ មួយជំហាននៅក្នុងការកាត់បន្ថយ ការពឹងផ្អែកទាំងស្រុងទៅលើផលិតផលនាំចេញ ដែលពីមុនគឺពឹងផ្អែក តែទៅលើផលិតផលឧស្សាហកម្មកាត់ដេរតែមួយមុខនោះ ។

នៅឆមាសទីមួយដើមឆ្នាំនេះ ការនាំចេញ នៃផលិតផលឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ គឺមានចំណែកត្រឹមតែប្រមាណជា ៧២,៦ ភាគរយប៉ុណ្ណោះ នៃចំណែក ផលិតផលនាំចេញសរុបរបស់កម្ពុជា ។

ដោយសារតែ នយោបាយជំរុញពិពិធកម្មផលិតផលនាំចេញនេះ ការនាំចេញផលិតផលផ្សេងៗ ជាពិសេសគឺអង្ករ កៅស៊ូ ជាដើម គឺកំពុងតែពង្រីកចំណែកភាគរយ នៃការនាំចេញរបស់កម្ពុជាហើយ ។

ការនាំចេញអង្កររបស់កម្ពុជា នៅក្នុងរយៈពេលនេះ បើទោះបីជាវាអាចនឹងលំបាក នៅក្នុងការអនុវត្តតាមផែនការជំរុញការនាំចេញអង្ករឲ្យបាន ១ លានតោននៅក្នុងឆ្នាំ២០១៥ នេះក៏ដោយក៏ស្ថានភាពនៃកំណើន គឺនៅក្នុងស្ថានភាពមួយ ដែលកើនឡើងយ៉ាងខ្ពស់ ធៀបនឹងរយៈពេលដដែល កាលពីឆ្នាំ ២០១៤ ។

តួលេខនៃការនាំចេញអង្ករ របស់សហព័ន្ធស្រូវអង្ករកម្ពុជា បានឲ្យដឹងថា នៅឆមាសទីមួយដើមឆ្នាំនេះ ការនាំចេញអង្កររបស់កម្ពុជា ទៅកាន់ទីផ្សារនៅក្រៅប្រទេស គឺមានបរិមាណប្រមាណជា ២៨៣.៨២៥ តោន កើនឡើងប្រមាណជា ៦០ ភាគរយធៀបនឹងបរិមាណនាំចេញកាលពីឆមាសទីមួយដើមឆ្នាំ២០១៤ ដែលមានចំនួនត្រឹមតែ ១៧៧.៩២៨ តោននោះ ។ ក្រៅពីអង្ករ ការនាំចេញកៅស៊ូស្ងួត ក៏មានសភាពកើនឡើង គួរឲ្យកត់សំគាល់ផងដែរ ទោះបីជាតម្លៃកៅស៊ូបានធ្លាក់ចុះ ប៉ុន្តែតម្លៃនៃការនាំចេញ គឺនៅតែមានកំណើន។

ចន្លោះពីខែ មករា ដល់ មិថុនា ឆ្នាំ ២០១៥ នេះ កម្ពុជានាំចេញកៅស៊ូស្ងួតបានប្រមាណជា ៦១.៩៦៩ តោន ពេល គឺមានការកើនឡើងប្រមាណជា ៤៧ភាគរយ ធៀបនឹងបរិមាណនាំចេញសរុប កាលពីរយៈពេលដដែលកាលពីឆ្នាំ២០១៤ គឺមានបរិមាណត្រឹមតែ ៤២.១៨៩ តោននោះ ។

នៅក្នុងរយៈពេលនេះ តម្លៃនៃជ័រកៅស៊ូនៅលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះប្រមាណជា ១៧ ភាគរយ ពេលគឺមានតម្លៃត្រឹមតែ ១.៥៣៣ ដុល្លារ ប៉ុណ្ណោះនៅក្នុងមួយតោន ប៉ុន្តែលទ្ធភាពនៃការនាំចេញរបស់កម្ពុជានៅក្នុងរង្វង់ ៦ ខែដើមឆ្នាំ គឺមានតម្លៃ រហូតដល់ទៅ ៨៤,២ លានដុល្លារ លើសពីរយៈពេលដដែល ឆ្នាំ២០១៤ ចំនួន ១២ ភាគរយ ដោយនៅពេលនោះ គឺមានត្រឹមតែ ៧៥ លានដុល្លារ ។

នៅក្នុងអំឡុងពេលនេះ ដៃគូពាណិជ្ជកម្មនាំចេញធំជាងគេ គឺសហគមន៍អឺរ៉ុប អាមេរិក កាណាដា ចិន ជប៉ុន កូរ៉េ។ល។ ខណៈដែល ដៃគូពាណិជ្ជកម្មនាំចូលវិញ គឺប្រទេសជិតខាង ដែលមានថៃ និង វៀតណាម ហើយអាចមានចិន។

នេះគឺជា ស្ថានភាពពាណិជ្ជកម្មកម្ពុជានៅក្នុងអំឡុងពេលឆមាសទីមួយ ដែលប្រទេសកំពុងតែស្ថិតនៅក្នុងស្ថានភាពដែលនយោបាយ មានសភាពនឹងនរ ប៉ុន្តែបន្ទាប់មក នៅដើមឆមាសទី ២ កំដៅនយោបាយនៅក្នុងប្រទេស ក៏បាន ចាប់ផ្ដើមកម្រើកឡើង ហើយកម្ពុជា នៅប្រឈមមុខនឹងបញ្ហាមួយចំនួននៅខាងក្រៅថែមទៀត គឺបញ្ហាវិបត្តិផ្សារហ៊ុន និងការធ្លាក់ចុះ នៃលុយយន់នៅចិន ដែលនោះ គឺជាផលប៉ះពាល់មួយដល់កម្ពុជា៕

*ដោយអរិយបុត្រ*

# មេដឹកនាំអ្នកការទូតនៅកម្ពុជាជំរុញឲ្យយុវជនយកចិត្តទុកដាក់នឹងសហាគមន៍អាស៊ាន

យុវជន និងយុវនារី ដែលមានចំនួនប្រមាណជា ៣៥ភាគរយ នៃប្រជាជនសរុបរបស់ប្រទេសកម្ពុជា ត្រូវបានប្រមុខមេដឹកនាំអ្នកការទូតនៅកម្ពុជា ជំរុញឲ្យរៀបចំខ្លួន និងយកចិត្តទុកដាក់នឹងបញ្ហាសមាហរណកម្មអាស៊ាន។

លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងជំរុញឲ្យយុវជន និងយុវនារីនៅក្នុងប្រទេសយកចិត្តទុកដាក់ នឹងបញ្ហាសមាហរណកម្មអាស៊ាននេះ នៅក្នុងអំឡុងពេលដែលលោក បានជួបជាមួយនឹងយុវជន និងយុវនារី ប្រមាណជាជិត ១.៥០០ នាក់ កាលពីអាទិត្យ ។

ប្រមុខមេដឹកនាំ អ្នកការទូតរូបនេះ បានថ្លែងជំរុញឲ្យយុវជន និង យុវនារីដែលតំណាងឲ្យ ប្រជាពលរដ្ឋ ៣៥ភាគរយ រៀបចំខ្លួនឲ្យហើយសម្រាប់សហគមន៍អាស៊ានមួយ ដែលនឹងក្លាយជា សហគមន៍មួយពិតប្រាកដ នៅក្នុងរង្វង់ចុងឆ្នាំនេះតែម្តង។

លោកបានបញ្ជាក់ថា "រយៈពេល គឺនៅតែបួនខែទៀតទេ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលទំព័រប្រវត្តិសាស្ត្រថ្មីមួយរបស់អាស៊ាន នឹងត្រូវបើក ដែលនេះ គឺជាសហគមន៍អាស៊ាន ហើយបណ្តាប្រទេសទាំងអស់ នៅក្នុងសហគមន៍នេះ នឹងក្លាយជាទីផ្សារតែមួយ"។

នៅចំពោះមុខយុវជន និង យុវនារីប្រមាណ ជាជិត ១.៥០០ នាក់នេះ លោកហោ ណាំហុង បានមានប្រសាសន៍ថា វាគឺជាឱកាសមួយ សម្រាប់កម្ពុជាហើយ បានបន្តក្រើនរំលឹកយុវជន និងយុវនារីឲ្យរៀបចំខ្លួន។

ជូ សុវណ្ណរិទ្ធ ជាយុវជនមួយរូប បានឲ្យដឹងថា ជាការពិត តាមការអានឯកសារនានា ក៏ដូចជាស្តាប់ការប្រឹក្សាយោបល់របស់អ្នកជំនាញ តាមទូរទស្សន៍ក្តីគ្រប់គ្នាតែងតែនិយាយអំពីឱកាស និងបញ្ហាប្រឈមនេះ ប៉ុន្តែសម្រាប់លោកជានិស្សិតមួយរូប ហាក់ដូចជាស្ទាក់ស្ទើរនៅក្នុងការនិយាយអំពីឱកាស។

លោកបានបញ្ជាក់ថា "តាមដែលខ្ញុំយល់ ឱកាសគឺប្រាកដជាមាន ប៉ុន្តែធៀបជាមួយនឹងប្រទេសដទៃវា គឺជាបញ្ហាដែលខ្ញុំព្រួយបារម្ភដែរ"។

ជុំវិញបញ្ហាសមាហរណកម្ម អាស៊ាននេះ លោក សុវណ្ណរិទ្ធ បានអះអាងថាមកដល់ពេលនេះ លោកមិនទាន់បានស៊ីជម្រៅអំពីបញ្ហាសេដ្ឋកិច្ចទេ ប៉ុន្តែអ្វីដែលជាការបារម្ភរបស់លោក ក៏ដូចជាយុវជនដទៃទៀត គឺទីផ្សារការងារដោយសារតែលោកបារម្ភថា សមត្ថភាពធនធានមនុស្សនៅកម្ពុជា ប្រហែលជានៅមិនទាន់ អាចប្រៀបធៀបជាមួយនឹងនិស្សិតនៅប្រទេសមួយចំនួន នៅអាស៊ានបាននៅឡើយទេ ជាពិសេស គឺបញ្ហាភាសាអង់គ្លេស។

លោកបានបញ្ជាក់ថា "ខ្ញុំដឹងចំណុចនេះដូច្នេះហើយ បានជាខ្ញុំកំពុងតែខិតខំនៅចំណុចនេះ ប៉ុន្តែសម្រាប់មិត្តភក្តិឯទៀត គឺពួកគេមិនមានឱកាស"។

លោកបានបន្តទៀតថា លោកមានមិត្តភ័ក្រជាច្រើន ដែលនៅក្នុងថ្នាក់ទទួលបានពិន្ទុល្អៗ លើផ្នែកមុខវិជ្ជាជំនាញផ្សេងៗ ប៉ុន្តែសម្រាប់ភាសា គឺហាក់នៅមានកម្រិត ដូច្នេះវាគឺជាបញ្ហាប្រឈមមួយសម្រាប់ពួកគេ ។

លោកបានបញ្ជាក់ថា "មុខវិជ្ជា ស្ថិតិ ទីផ្សារ គ្រប់គ្រង គឺភាគច្រើនមិត្តភក្តិខ្ញុំសុទ្ធតែបានពិន្ទុល្អ តែសម្រាប់មុខជំនាញភាសាបរទេស មិត្តភក្តិដែលមកពីតាមខេត្ត ភាគច្រើន ដូចជាមិនសូវមានអ្នកបានពិន្ទុល្អ "។

កញ្ញា គៀត ចិន្តា ជាយុវនារីនិស្សិតមួយរូប មកពីខេត្តកំពត បានឲ្យដឹងថាមកដល់ពេលនេះ ទាំងគ្រូ ទាំងមិត្តភក្តិគឺសុទ្ធតែរំលឹក និងដាស់តឿន ក៏ដូចជាតែងតែនិយាយអំពី សមាហរណកម្មអាស៊ាននេះ ហើយសម្រាប់កញ្ញា ក៏បានកំពុងតែត្រៀមខ្លួនផងដែរ ប៉ុន្តែអ្វីដែលកញ្ញាបានត្រៀមខ្លួន គឺហាក់ដូចជាពិបាក ។

កញ្ញា បានបញ្ជាក់ថា "ពួកខ្ញុំមកពីខេត្តតបឹង គឺមានអារម្មណ៍ថាថ្មី នៅពេលដែលគេនិយាយអំពីអាស៊ាន ប៉ុន្តែកំពុងតែខិតខំ "។

កញ្ញា បានបន្តថា ពេលរៀននៅតាមខេត្ត គឺហាក់មិនសូវជាមានគេនិយាយច្រើនទេអំពីបញ្ហាអាស៊ាន ក៏ដូចជាបញ្ហាអន្តរជាតិផ្សេងៗ ប៉ុន្តែពេលដែលមករៀននៅភ្នំពេញ គឺគេនិយាយច្រើន ហេតុដូច្នេះ ហើយបានជាកញ្ញាកំពុងតែខិតខំស្វែងយល់អំពី សហគមន៍នេះ ហើយក៏កំពុងតែ ព្យាយាមសិក្សាកំរិតភាសា។

កញ្ញាបានបន្តថា "រឿងមុខវិជ្ជាជំនាញផ្សេងៗ ខ្ញុំហាក់ដូចជា មិនភ័យបារម្ភទេ ប៉ុន្តែបញ្ហានៅត្រង់ភាសា ដោយសារតែមិត្តភក្តិខ្លះ គេរៀនយូរហើយ ខ្លះតាំងពីតូចមក ប៉ុន្តែខ្ញុំ គឺទើបតែចាប់ផ្តើម គឺមានអារម្មណ៍ថាលំបាក"។

កញ្ញា បានបញ្ជាក់ថា "មុខវិជ្ជាផ្សេងៗ គឺរៀនមកតាំងពីតូចៗ ដូចគេដូចឯង តែភាសាគឺ ខ្ញុំទើបតែរៀនខ្លាំងតែពីរ ទៅបីឆ្នាំនេះប៉ុណ្ណោះ"។

ជុំវិញបញ្ហាជំនាញការងារនេះ លោក ហោ ណាំហុង បានប្រកាសទទួលស្គាល់ថា នេះគឺជាបញ្ហាប្រឈម ។

លោកបានបញ្ជាក់ នៅក្នុងពេលជួបជាមួយនឹង និស្សិតទាំងអស់នោះថា "សម្រាប់បញ្ហាជំនាញការងារ វាពិតជាបញ្ហាប្រឈមមួយរបស់កម្ពុជា ប៉ុន្តែនៅលើពិភពលោកនេះ យើងមិនអាចបិទទ្វារ ហើយរស់នៅតែម្នាក់ឯងបានទេ យើងត្រូវតែប្រឹងប្រែងដើម្បីជំនះវា"៕

*ដោយអរិយបុត្រ*



*រូបភាព: AKP*

# យុវជនយុវនារីស្វែងយល់ពីការត្រាស់ហៅ

ព្រះសហគមន៍កាតូលិកកម្ពុជា បានរៀបចំការបោះជំរំ នៃការត្រាស់ហៅសម្រាប់យុវជនយុវនារី ទាំងបីភូមិភាគ ដើម្បីរិះគិតពីជីវិត បព្វជិតបព្វជីតាជីវិតជាក្រុមគ្រួសារ និងជីវិតរស់នៅលីវ កម្មវិធីនេះបានរៀបចំឡើង កាលពីថ្ងៃទី ២១-២២ សីហា ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ជ្មឹតអីស្លែរ ដឹកនាំដោយគណៈកម្មការ សម្រាប់ការត្រាស់ហៅ ហើយមានយុវជនយុវនារីចូល រួមចំនួន២៣៦នាក់ មកពីព្រះសហគមន៍នានាក្នុងប្រទេសកម្ពុជា។

ក្នុងថ្ងៃដំបូងនៃការបោះជំរំនេះលោកអភិបាល អូលីវីយេ បានណែនាំអត្ថបទមួយចំនួន ពីទំនាក់ទំនង រវាងព្រះជាម្ចាស់ និងយើងម្នាក់ៗតាមព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ និងសម្ព័ន្ធមេត្រីថ្មី។ លោកអូលីវីយេ បានលើកទឹកចិត្តយុវជនទាំងនោះ ដោយឲ្យគេទទួលស្គាល់ថា ជីវិតបានមកពីព្រះជាម្ចាស់ មានលក្ខណៈដូចព្រះជាម្ចាស់ និងជាតំណាងព្រះជាម្ចាស់។ ក្នុងកម្មវិធីនោះដែរ យុវជនក៏មានពេលវេលាសម្រាប់ផ្ទាល់ខ្លួនក្នុងការរិះគិត ដោយស្ងៀមស្ងាត់ពីអត្ថបទទាំងនោះផងដែរ។

ជាមួយគ្នានេះ លោកបានបង្ហាញឲ្យយល់ពីរបៀប នៃការឆ្លើយតបនៃការត្រាស់ហៅ ដោយរស់នៅក្នុងបរិយាកាសព្រះជាម្ចាស់ គឺព្យាយាមអធិដ្ឋានស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ និងចូលរួមអភិបូជា ជាពិសេសត្រូវមានគំរូ ហើយព្រះយេស៊ូជាគំរូផ្ទាល់ ដែលលះបង់អ្វីៗទាំងអស់ និងណែនាំយើងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។

នៅថ្ងៃទីពីរ យុវជនយុវនារីទាំងអស់បានរិះគិតអំពីប្រធានបទ "ព្រះជាម្ចាស់បានត្រាស់ហៅយើង ដើម្បីបម្រើព្រះអង្គបម្រើបងប្អូន តាមរបៀបផ្សេងៗ"។ ក្នុងនោះ មានរិះគិតអំពីការបម្រើបងប្អូនក្នុងជីវិតជាអ្នកបួស ដោយមានការបង្ហាញ និង ផ្តល់សាក្ខីភាពពីក្រុមគ្រួសារនានា នៃបព្វជិតបព្វជីតាផងដែរ។

លោក អ៊ុនស៊ុន ជាបូជាចារ្យទទួលខុសត្រូវលើក្រុមនេះ បានឲ្យដឹងថា ៖ កម្មវិធីនេះធ្វើឡើង ដើម្បីជួយដល់យុវជនយុវនារី ក្នុងការរិះគិតពីអនាគតរបស់ខ្លួន និង ស្វែងយល់ពីអ្វីជាការត្រាស់ហៅ ដោយមកស្តាប់ព្រះបន្ទូលពីអ្វីដែលព្រះជាម្ចាស់បានអប់រំយើង និងចាត់ឲ្យយើងដូចសាវ័កពីដំបូង។ លោកបូជាចារ្យបញ្ជាក់ថា "នេះជាពេលវេលាមួយដើម្បីឲ្យប្អូនៗទាំងនេះ ចេះរកផ្លូវអនាគតរបស់ខ្លួនបានហើយ ដើម្បីឆ្លើយតបជាមួយ ការត្រាស់ហៅរបស់ព្រះជាម្ចាស់បានលុះត្រាតែពួកគេ ហ៊ានធ្វើការសម្រេចចិត្តដោយខ្លួនឯង តែអ្វីដែលសំខាន់ គឺយើងត្រូវការអប់រំ និងប្រមូលពួកគេដូចព្រះយេស៊ូ ដែលតែងតែសាបព្រួសដែរ"។

លោកស៊ុន បានឲ្យដឹងទៀតថា ក្រុមនេះ បានកកើតមានឡើង តាំងពីឆ្នាំ១៩៩៨មក និងឃើញថា បានទទួលផលផ្លែជាច្រើន ដោយសព្វថ្ងៃយើងមានលោកបូជាចារ្យ៧នាក់ និងមានបងស្រីផ្សេងៗទៀត ដែលកើតចេញពីក្រុមនេះ។

ក្រុមយុវជនយុវនារីខ្មែរទាំងនេះ ជាក្រុមមួយ ដែលភាគច្រើន បានទទួលអគ្គសញ្ញាជ្រមុជទឹកថ្មីៗ និងបានទទួលការអប់រំ ព្រមទាំងមានសកម្មភាពជាមួយក្រុមនានាក្នុងព្រះសហគមន៍ ។ លោកបូជាចារ្យ សុន បន្តទៀតថា ព្រះសហគមន៍ចង់ឲ្យពួកគេ មានជំរើសក្នុងជីវិត និងមានការរិះគិតពីអត្ថន័យនៃជីវិតផ្ទាល់ខ្លួន និងទំនាក់ទំនងជាមួយព្រះជាម្ចាស់ តាមរយៈទស្សនារឿងសន្តបុគ្គល និងស្តាប់ពីសក្ខីភាពរបស់វាគ្មិនជាដើម។

យុវជន ឡេង សម្បត្តិបាននិយាយថា រយៈពេល៣ថ្ងៃមកនេះ លោកបានយល់ថាបទពិសោធន៍ ដែលបងប្រុសបងស្រីបានពន្យល់ពីជីវិតអ្នកបួស បានជ្រាបចូលទៅក្នុងចិត្ត និងចង់បានជីវិតរស់នៅជាអ្នកបួស ដូចពួកគាត់។ សម្បត្តិ និយាយទៀតថា "ជីវិតរបស់ពួកគាត់មានទុក្ខលំបាកច្រើន តែមានតែការជឿលើព្រះជាម្ចាស់ តែមួយគត់ ដោយមិនចាំបាច់ គិតថា មនុស្ស (ឯទៀត) គិតថាយ៉ាងនេះ យ៉ាងនោះនោះទេ។ ព្រោះមានតែការជឿ និងការស្រឡាញ់គឺគ្រប់គ្រាន់ហើយ"។

កញ្ញាបូ ម៉ាច អាយុ២៧ឆ្នាំ មកពីព្រះសហគមន៍ម្នាវ ខេត្តកំពង់ធំ បាននិយាយថា ពីមុននាងធ្លាប់ចាប់អារម្មណ៍ពីជីវិតអ្នកបួស ប៉ុន្តែហាក់ដូចជាមិនសូវយល់ប៉ុន្មានឡើយ និងបន្ទាប់ពីបានចូលរួម ក្នុងកម្មវិធីបោះជំរំនេះបានធ្វើឲ្យម៉ាច យល់កាន់តែច្បាស់ពីជីវិតអ្នកបួស និងមានសេចក្តីស្រឡាញ់កាន់តែច្រើនចំពោះអ្នកដទៃ។

យុវតីដដែលនេះបន្តថា "សំខាន់ខ្ញុំត្រូវតែអធិដ្ឋានជានិច្ច ដើម្បីឲ្យខ្ញុំមានជំនឿរឹងមាំមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ និងអាចឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់"។

នាព្រឹកថ្ងៃទី៣ ដែលជាថ្ងៃចុងក្រោយ នៃកម្មវិធីបោះជំរុំនេះ យុវជនទាំងអស់ បានចូលរួមថ្វាយអភិបូជារួមជាមួយគ្រីស្តបរិស័ទ នៅតំបន់ព្រះសីហនុ និងបង្កើនទំនាក់ទំនងជាមួយគ្នាបន្ថែមទៀត ដោយការកំសាន្តនៅតាមឆ្នេរសមុទ្រ។

នេះជាលើកទី៣ ហើយដែលមានការបោះជំរំ នៃក្រុមអេម៉ាណូអែល រួមជាមួយក្រុមសាម៉ូអែល ដែលមានរួមគ្នាទាំងបីភូមិភាគ នៅក្នុងមណ្ឌលសកម្មភាពក្រុងព្រះសីហនុ។ ហើយរយៈពេល២ឆ្នាំកន្លងមកនេះ ក្រុមនីមួយៗ បានជួបជុំគ្នាចំនួន៦ដង ក្នុងមួយឆ្នាំ ដើម្បីរិះគិតពីការត្រាស់ហៅ៕

*ដោយដាលីស*



*កម្មវិធីបោះជំរំនៃការត្រាស់ហៅសម្រាប់យុវជន យុវនារីទាំងបីភូមិភាគនៅព្រះសហគមន៍សន្តមីកាអែល ក្រុងព្រះសីហនុ កាលពីថ្ងៃទី២១- ២២ សីហា ឆ្នាំ២០១៥*

# វិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ ទទួលលទ្ធផលគួរជាទីមោទនៈនៅក្នុងការប្រឡងសញ្ញាប័ត្រទុតិយភូមិ



វិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ ជាសាលាចំណេះដឹងទូទៅមួយនៅកម្ពុជា ដែលកំពុងតែដំណើរការអប់រំ ដោយព្រះសហគមន៍កាតូលិកបានទទួលលទ្ធផលដ៏ត្រចះត្រចង់ នៅក្នុងការប្រឡងសញ្ញាប័ត្រទុតិយភូមិ ដែលដំណើរការកាលពីថ្ងៃទី២៤ និង ២៥ ខែ សីហា ឆ្នាំ ២០១៥ កន្លងទៅនេះ ។

យោងទៅតាមលទ្ធផល ដែលបានប្រកាសកាលពីថ្ងៃទី ១៣ ខែ កញ្ញា ដោយក្រសួងអប់រំ យុវជន និង កីឡា បានឲ្យដឹងថា នៅក្នុងចំណោមសិស្សសរុបចំនួន ៣៤នាក់ ដែលបានចូលរួមសម័យប្រឡង គឺបានជាប់ជាស្ថាពរចំនួន ៣០ ពោលគឺធ្លាក់ត្រឹមតែ ៤ នាក់ប៉ុណ្ណោះ។

អ្នកស្រី ឡៃ មករា ជានាយិការងវិទ្យាល័យ និងចំណេះដឹងទូទៅនៃសាលាសន្ត ហ្វ្រង់ស្វ័រ បានមានប្រសាសន៍ឲ្យដឹងថា នៅក្នុងចំណោមអ្នកដែលជាប់ គឺថាយើងមានយុវសិស្សពីររូបបានទទួលនិទ្ទេស A នេះគឺជាមោទនៈភាពមែនទែន សម្រាប់សាលារបស់យើង ។

អ្នកស្រីបានបញ្ជាក់ថា "នេះគឺជាលើកទីមួយ និងក៏ជាមោទនភាពដែរ ដែលវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ មានសិស្សថ្នាក់ទី១២ ចូលរួមប្រលងយកសញ្ញាបត្រទុតិយភូមិ កំរិតថ្នាក់ជាតិ ទទួលបាននិទ្ទេស A ចំនួន២នាក់ និង និទ្ទេសល្អផ្សេងៗទៀត មានចំនួនច្រើនជាងឆ្នាំមុន"។

នាយិការូបនេះបានបន្តថា សម្រាប់ខ្ញុំមានចិត្តសប្បាយរីករាយជាខ្លាំង ជាមួយលទ្ធផល ដែលវិទ្យាល័យ សន្ត ហ្វ្រង់ស្វ័រទទួលបាន។ ទាំងនេះបានបង្ហាញឲ្យឃើញ នូវគុណភាពនៃការអប់រំ ក៏ដូចជាការខិតខំប្រឹងប្រែងសិក្សារបស់សិស្សនៃវិទ្យាល័យយើង ។

មកដល់ពេលនេះ សាលាសន្ត ហ្វ្រង់ស្វ័រ គឺជាសាលា ដែលកំពុងតែផ្តល់ចំណេះដឹងទូទៅមួយ ដល់កូនខ្មែរដែលមានទីតាំងស្ថិតនៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ សាលានេះ បានដំណើរការ និងបង្កើតឡើង ដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។ សាលានេះបានបង្កើតឡើង ហើយបានចូលរួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស ដល់គ្រួសារក្រីក្រ ក្មេងកំព្រា និងអ្នកដែលគ្មានទីពឹង ក៏ដូចជាកូនខ្មែរទូទៅជាច្រើននាក់ នៅក្រោមគំនិតផ្តួចផ្តើមដោយលោក អូលីវៀ ជឺតអីស្លែរ ជាអភិបាល នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញផ្ទាល់ ។

លោកស្រីបានឲ្យដឹងថា យុវសិស្សទាំងពីរនាក់ដែលជាប់និទ្ទេស A នោះ គឺជាយុវជន ប៊ិច ពិសិដ្ឋរតនៈ និង យុវនារី កញ្ញាអិន ចរិយា។ អ្នកទាំងពីររស់នៅភូមិអង្គតាធិល ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ នៅក្នុងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥នេះ យុវជនទាំងពីររូប គឺជាយុវជនតំណាង ឲ្យយុវសិស្សឆ្នើម មកពីស្រុកត្រាំកក់ ខេត្តតាកែវ ដែលបានធ្វើដំណើរមកចូលរួមកម្មវិធី ទទួលជួបសំណេះសំណាល ជាមួយនឹងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងយុវសិស្សនិទ្ទេស A ទាំងចំនួន ១០៨ រូប ដែលបានប្រឡងបានជ័យលាភី កាលពីការប្រឡងនាខែ សីហា កន្លងទៅនេះ។

យុវសិស្ស ប៊ិច ពិសិដ្ឋរតនៈ អាយុ ១៨ឆ្នាំបានឲ្យដឹងថាប្អូនអំណរសប្បាយរីករាយ ចំពោះលទ្ធផល នៃការប្រលងនេះព្រោះនេះជាសមត្ថភាពផ្ទាល់ របស់ប្អូនតែម្តង។ សម្រាប់ការសិក្សា របស់ប្អូននៅវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ គឺមានពេលវេលាច្រើនក្នុងការស្វ័យសិក្សាក្រៅម៉ោងសិក្សាបន្ថែមទៀត ។ កញ្ញា អិន ចរិយា ជ័យលាភីនិទ្ទេស A មួយរូបទៀតបានអះអាងថា ប្អូនមានអារម្មណ៍សប្បាយចិត្តមែនទែន ដែលមិននឹកស្មានថា លទ្ធផលប្រលងរបស់ខ្លួនទទួលបាននិទ្ទេសល្អដូច្នេះនោះទេ ៕

*ដោយអរិយបុត្រ*

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

***មាត្រាទី ២៦៖***

នៅពេលមានថ្មើរជើងឆ្លងកាត់ អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម៖

១. គ្រប់ករណីទាំងអស់ អ្នកបើកបរត្រូវតែឈប់នៅពេលថ្មើរជើងកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់នៅកន្លែងដែលមានគំនូសសញ្ញា សម្រាប់អ្នកថ្មើរជើងឆ្លងកាត់។

២. នៅត្រង់កន្លែងផ្លូវប្រសព្វ ឬនៅជិតកៀកផ្លូវប្រសព្វអ្នកបើកបរត្រូវហាមឃាត់ក្នុងការធ្វើឲ្យអាក់ខាន ឬរាំងស្ទះដល់ថ្មើរជើង ដែលកំពុងឆ្លងកាត់ទ្រូងផ្លូវ ទោះបីគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ក៏ដោយ។

៣. ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ នៅត្រង់ផ្លូវប្រសព្វ ដែលមានភ្លើងសញ្ញាចរាចរណ៍ ឬមានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ ទោះបីមានភ្លើងពណ៌បៃតង ឬមានបញ្ជាភ្នាក់ងារឲ្យទៅមុខក៏ដោយ អ្នកបើកបរមិនត្រូវធ្វើឲ្យរំខាន ឬ ធ្វើឲ្យរាំងស្ទះ ដល់ថ្មើរជើងដែលកំពុងឆ្លងកាត់នៅលើគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ឡើយ។ ចំពោះអ្នកបើកបរ ដែលបត់ចូលទ្រូងផ្លូវផ្សេងទៀត ហើយនៅលើទ្រូងផ្លូវនោះ មានថ្មើរជើងកំពុងឆ្លងកាត់ អ្នកបើកបរត្រូវបន្ថយល្បឿន បើចាំបាច់ត្រូវឈប់ ដើម្បីផ្តល់សិទ្ធិឲ្យថ្មើរជើងឆ្លងកាត់រួចរាល់សិន។

ករណីមានគំនូសសញ្ញា សម្រាប់ថ្មើរជើងឆ្លងកាត់ នៅត្រង់ផ្លូវប្រសព្វដែលគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារបញ្ជាចរាចរណ៍ នៅទីនោះ អ្នកបើកបរត្រូវបន្ថយល្បឿន ឬត្រូវឈប់ ដើម្បីផ្តល់សិទ្ធិឲ្យថ្មើរជើងដែលកំពុងឆ្លងកាត់ ឬរៀបនឹងឆ្លងកាត់ទៅមុន។



*រូបថត: internet*




*រូបភាពឯកសារ៖ មាតុភូមិនិវត្តរបស់ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ កាលពីឆ្នាំ២០១៤ (សម្បត្តិ)*

# ស្ថានភាពកម្មករខ្មែរមួយក្រុមនៅលើទឹកដីថៃ

កម្មករសំណង់ រៀបចំសួនច្បារ កម្មករជួសជុល និង កម្មករពហុជំនាញ គឺកំពុងតែកាន់កាប់ ការងារប្រើកម្លាំង នៅតាមរីសត (Resort) មួយចំនួននៅតាមបណ្តាខេត្តនៅក្នុងប្រទេសថៃដោយត្រូវបានគេបែងចែកជាក្រុមៗ ដឹកតាមខ្លួនចល័តសឹងតែពេញប្រទេស។

ក្រុមកម្មករ ជនជាតិខ្មែរមួយក្រុមដែលបានជួបជាមួយនឹង អ្នកសារព័ត៌-មានអ្នកនាំសារ នៅក្នុងពេលធ្វើដំណើរកំសាន្តនៅក្នុងប្រទេសថៃ កាលពីអំឡុងចុងខែ សីហា ឆ្នាំ ២០១៥ នាហាងសីវែន អេឡីវែន នៅក្នុងខេត្ត សាមុតសុងក្រាន។ ក្រុមកម្មករ ដែលមានគ្នាប្រមាណជា ១០នាក់ អង្គុយនៅលើឡាន ប្រភេទដឹកទំនិញខ្នាតតូចមួយគ្រឿង បានអះអាងថា ពួកគេបានមកធ្វើការនៅក្នុងប្រទេសថៃនេះ ប្រហែលជា ៥ខែហើយ ពោលគឺចាប់តាំងពីក្រោយចូលឆ្នាំខ្មែរមក ។

លោក គិត សុវណ្ណ (ឈ្មោះដែលអ្នកសារព័ត៌មានបានដាក់ឲ្យ) ជាកម្មករខ្មែរមួយរូប នៅលើឡាននោះ បានឲ្យដឹងថា ពួកគេគឺមកពីភូមិស្រុកតែមួយ ហើយបានមកធ្វើការនៅទីនេះ ជាមួយគ្នាជាក្រុមតែម្តង ។

សុវណ្ណ បានអះអាងថា ពួកគេគឺមកពីស្រុកបន្ទាយឆ្មា ខេត្ត បន្ទាយមានជ័យ ហើយ អ្នកដែលមកធ្វើការនៅទីនេះ គឺមានអ្នកខ្លះមកទាំងប្តីទាំងប្រពន្ធ ដោយបានប្រាក់ឈ្នួលគិតជាថ្ងៃ។ លោកបានបន្តថា អ្នកដែលចេះច្រើន ធ្វើការច្រើនគឺបានប្រាក់ខ្ពស់ទៅ ប៉ុន្តែសម្រាប់ក្រុមរបស់ពួកគាត់ គឺបានប្រាក់ខែចាប់ពី ៣០០បាត ទៅ ៥០០បាត នៅក្នុងមួយថ្ងៃ ។

ជុំវិញស្ថានភាពការងារនិងស្ថានភាពជីវភាពរបស់ពួកគេដែលបានមកធ្វើការនៅក្នុងប្រទេសថៃ កម្មករ និងកម្មការិនីចំណាកស្រុកខ្មែរនៅលើឡាននេះ បានប្រាប់ម្នាក់មួយម៉ាត់ ហើយដែលអ្នកសារព័ត៌មានរបស់អ្នកនាំសារ សូមសង្ខេបអត្ថន័យបានថា ស្ថានភាពគឺវាខុសគ្នាទៅតាមស្ថានភាពការងារ ថៅកែ ឬក្រុម ។

ពួកគេបានរៀបរាប់ថា សម្រាប់ក្រុមពួកគេមិនអីទេ ហើយនៅក្នុងរយៈពេលប្រមាណជា ៥ខែ ដែលពួកគេបានធ្វើការនៅទីនេះ គឺទទួលការទំនុកបម្រុងការថែទាំ ការការពារ និងបង់ប្រាក់ឈ្នួលឲ្យគ្រប់គ្រាន់តាមការងារ ហើយពួកគេមានសេរីភាពដើរទៅណាក៏បាន ប៉ុន្តែគ្រាន់តែមិនហ៊ានដើរ ព្រោះវាមិនស្វស្គាល់ ហើយអ្នកដែលគេធ្លាប់ស្គាល់ធ្លាប់មក គឺគេទៅណាក៏បាន។

ពួកគេបានបន្តទៀតថា ជាការពិតការងារនៅទីនេះ អត់មានថ្ងៃសម្រាកទេ ដោយពេលព្រឹក ក្រោយពេលស្រស់ស្រូបរួចរាល់ គឺថៅកែបើកឡានដើរដាក់គ្រប់កន្លែង ពេលខ្លះត្រូវជិះឡាន ២ ម៉ោង ពីកន្លែងដេកកាត់ទីក្រុងបាងកកឆ្ងាយទៅទៀតក៏មាន ដល់ពេលល្ងាចបានដើរប្រមូលមកកន្លែងដេកវិញ។

ពួកគេបានរៀបរាប់ថា ធ្វើការនៅទីនេះដូចជាគ្មានអ្នកណាចាប់ទេ ដោយសារកន្លងមកថៅកែបានដឹកពួកគេកាត់ប៉ូលីស កាត់កន្លែងត្រួតពិនិត្យជាញឹកតែមិនដែលមានអ្នកណាហៅសួរអីទេ ។

ជុំវិញបញ្ហាប័ណ្ណធ្វើការ និងភាពស្របច្បាប់របស់ពួកគេ ក្រុមកម្មករខ្មែរមួយក្រុមនេះ បានអះអាងថា ពួកគេត្រូវបានថៅកែនាំទៅធ្វើហើយ ប៉ុន្តែមិនទាន់ឃើញគេឲ្យមក ។

លោក ថាឡាត សារ៉ កម្មករជនជាតិខ្មែរសុរិនមួយរូប ដែលអង្គុយនៅក្នុងឡានជាមួយនេះ បានបញ្ជាក់ថា "ថៅកែគាត់នាំទៅធ្វើហើយ តែគេថាមិនទាន់បាន។ គេថាចាំធ្វើឲ្យពួកភូមា និង ឡាវសិនចាំធ្វើឲ្យខ្មែរ"។

កម្មករសញ្ជាតិថៃ ដើមកំណើតខ្មែរសុរិនរូបនេះ បានអះអាងថា "នៅក្នុងចំណោមកម្មករមួយឡាននេះ មានអ្នកខ្លះមកធ្វើការនៅទីនេះបាន ៥ ឆ្នាំហើយក៏ចេះនិយាយថៃបានដែរ ពេលនេះឲ្យតែវាការជាមួយនឹងក្រមុំថៃ វាក្លាយជាថៃបាត់ហើយ" ។

លោកបានបន្តថា "អានេះដើរលេងពេញតែថៃហ្នឹង លុយមិនសូវសល់ទេ ផឹកក៏ផឹកដែរ អានោះ (សុវណ្ណ) គឺប្រហែលជាសល់លុយច្រើន ពីព្រោះវាមកជាមួយប្រពន្ធ"។

សុវណ្ណ បានឲ្យដឹងថា រូបគេនិងប្រពន្ធចង់ទៅស្រុកវិញ នៅពេលភ្ជុំដោយសារតែប្រពន្ធក៏ជិតគ្រប់ខែដែរហើយ។

លោកបានបញ្ជាក់ថា "ថៅកែគាត់ឲ្យនៅសម្រាលទីនេះដែរ (នៅស្រុកថៃ) តែខ្ញុំមិនចង់ ពីព្រោះវាលំបាកអត់មានចាស់ទុំ"។

សុវណ្ណ បានឲ្យដឹងថា ពេលភ្ជុំរួចហើយកូនកើតរួច រូបគេប្រហែលជាវិលមកធ្វើការជាមួយនឹងថៅកែនេះវិញ ដោយសារតែគាត់ យកចិត្តទុកដាក់ជាមួយនឹងកម្មករ ដោយសារគាត់ក៏ជាខ្មែរសុរិនដែរ។

សុវណ្ណ បានបន្តថា នៅពេលដែលឆ្លងកាត់ព្រំដែន មករកការងារនៅថៃនេះ គឺលំបាកតែនៅខាងខ្មែរទេ តែពេលដែលបានចូលមកដល់ព្រំដែនថៃ ថៅកែគាត់ជួយគ្រប់យ៉ាង។ លោកបានបន្តថា នៅខាងខ្មែរប៉ូលីសខ្មែរកាលនោះដូចជាទារលុយពីពួកយើងម្នាក់ៗពី ពីរ ទៅបីពាន់បាតឯណោះ តែដល់ពេលទៅដល់ថៃដូចជាមិនមានអី៕

*ដោយអរិយបុត្រ*

# រាជរដ្ឋាភិបាលប្រកាសពីភាពត្រឹមត្រូវនៃផែនទីដែលមានស្រាប់

ក្រោយការផ្ទៀងផ្ទាត់ ជាមួយនឹងផែនទី ១៨ផ្ទាំង ដែលបានខ្ចីមកពីអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសអំពីភាពស្របច្បាប់ និងភាពត្រឹមត្រូវនៃផែនទី ដែលមានស្រាប់ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាព្រំដែនជាមួយនឹងប្រទេសជិតខាង ។

ផែនទីដែលកម្ពុជាខ្ចីនោះ គឺបានមកដល់កម្ពុជាកាលពីថ្ងៃទី ១៨ ខែ សីហា និងបានប្រគល់ ដោយមន្ត្រីអង្គការសហប្រជាជាតិ និងបានផ្ទៀងផ្ទាត់នៅថ្ងៃទី២០ ខែដដែល ក្រោមវត្តមានសង្កេតការណ៍ ពីតំណាងគណបក្សនយោបាយបី គឺគណបក្សប្រជាជនកម្ពុជា សង្គ្រោះជាតិ និងគណបក្សហ៊្វុនស៊ិនប៉ិច តំណាងសភា ព្រឹទ្ធសភា ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមក្រុមប្រឹក្សាធម្មនុញ្ញ និង តំណាងរាជបណ្ឌិតសភា កម្ពុជា ។

លោក វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិ ទទួលបន្ទុកព្រំដែន ក៏បានថ្លែងថា លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីនេះ គឺដូចគ្នាទាំងស្រុងហើយទៅនឹងផែនទី ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រើប្រាស់ក្នុងការបោះបង្គោលកំណត់ព្រំដែន ជាមួយប្រទេសវៀតណាម។

លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស បានថ្លែងរំពឹងថា គ្រប់និន្នាការនយោបាយទាំងអស់ រួមទាំងប្រជាពលរដ្ឋផង នឹងជ្រះស្រឡះក្នុងចិត្ត ហើយមានជំនឿមកលើរាជរដ្ឋាភិបាល ក្នុងការបោះបង្គោលកំណត់ព្រំដែន ជាមួយប្រទេសជិតខាង៕

# អឺរ៉ុបកំពុងតែប្រឈមមុខនឹងវិបត្តិជនភៀសខ្លួន

សហភាពអឺរ៉ុប បានស្នើឱ្យមានកិច្ចពិភាក្សាជាបន្ទាន់មួយ ដើម្បីដោះស្រាយវិបត្តិនៃជនចំណាកស្រុក ដែលកំពុងតែកើនឡើងដ៏គំហុក មកកាន់បណ្តាប្រទេសនៅក្នុងសហភាពអឺរ៉ុប។

ប្រទេសលុចហ្សំបួរ ដែលជាប្រធានសហភាពអឺរ៉ុបនៅក្នុងឆ្នាំនេះ បាននិយាយថា រដ្ឋមន្ត្រីមហាផ្ទៃពីបណ្តាប្រទេសសមាជិកទាំងអស់ ២៨ នឹងធ្វើកិច្ចប្រជុំវិសាមញ្ញមួយនៅថ្ងៃទី ១៤ ខែកញ្ញា ដោយសារតែវិបត្តិនេះកើនដល់កម្រិតមួយមិនធ្លាប់មានពីមុនមក។

របាយការណ៍នេះ បានកើតឡើងមួយសប្តាហ៍ ដែលគេបានប្រទះឃើញមនុស្សរាប់រយនាក់ផ្សេងទៀត បានលង់ទឹក នៅតំបន់សមុទ្រមេឌីទែរ៉ានេ ហើយ ៧១នាក់ទៀត បានស្លាប់នៅក្នុងរថយន្តដឹកទំនិញមួយនៅប្រទេសអូទ្រីស។

ជនចំណាកស្រុក ច្រើនបំផុតនៅក្នុងកំណត់ត្រា ចំនួន១០៧.៥០០នាក់ បានទៅដល់ព្រំដែនសហភាពអឺរ៉ុបកាលពីខែមុន។

ជុំវិញបញ្ហា ជនចំណាកស្រុកនេះ អង្គការសហប្រជាជាតិ បាននិយាយថា ជម្លោះដែលបន្តញាំញី នៅស៊ីរី គឺជាកត្តាចម្បងនៅពីក្រោយការកើនឡើង នៃចំនួនជនចំណាកស្រុក។

នៅក្នុងចំណោម បណ្តាប្រទេសទាំងអស់នៅអឺរ៉ុប ប្រទេសក្រិក អ៊ីតាលី និងហុងគ្រី កំពុងតែប្រឈមមុខយ៉ាងខ្លាំងជាមួយនឹងកំណើន ជនចំណាកស្រុក មិនត្រឹមតែមកពីស៊ីរីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅមជ្ឈិមបូព៌ានិងអាហ្វ្រិក។

ជុំវិញបញ្ហា ជនចំណាកស្រុកនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏ធ្លាប់បានប្រកាសជាបន្តបន្ទាប់ និង បានស្នើសុំឲ្យមានការសង្គ្រោះ ជនងាយរងគ្រោះទាំងនេះ ៕

# ថៃគ្រោងជួលគ្រូបង្រៀនភាសាអង់គ្លេសពីហ្វីលីពិន

កាសែត ដឹហ្វីលីពីនស្តា បានរាយការណ៍ថា នៅក្នុងដំណើរបំពេញទស្សនកិច្ចរបស់លោក ប្រាយុទ្ធ ចាន់អូចា នៅក្នុងទឹកដីហ្វីលីពិន កាលពីពេលថ្មីៗនេះ លោកបានរំលឹកថា រដ្ឋាភិបាលក្រុងបាងកករបស់លោក អាចនឹងរំពឹងអំពីការជ្រើសរើសគ្រូបង្រៀន ភាសាអង់គ្លេសពីហ្វីលីពិន ប្រមាណជា ៤.០០០ នាក់។

ប្រភពដដែលបានឲ្យដឹងថា លោក ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃ បានលើក ឡើងពីផែនការនេះ នៅពេលដែលលោកជួប ជាមួយនឹងប្រធានាធិបតី ហ្វីលីពិន នៅក្នុងដំណើរទស្សនកិច្ចជាផ្លូវការ កាលពីក្នុងចុងខែ សីហា ថ្មីៗនេះ។

ប្រភពដដែលបានឲ្យដឹងថា គោលគំនិតនេះគឺជាផ្នែកមួយនៃផែនការដែលរដ្ឋាភិបាលថៃ បានគ្រោងនឹងរៀបចំឡើង ដើម្បីពង្រឹងខ្លួនសម្រាប់ជំរុញដំណើការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ឲ្យបានស៊ីជម្រៅ ដែលអាស៊ាននឹងប្រកាសជាផ្លូវការ នូវសហគមន៍អាស៊ាន នៅក្នុងចុងឆ្នាំនេះ៕

# អៀង ធីរិទ្ធ ទទួលមរណភាព

ស្ត្រីជាមេដឹកនាំខ្មែរក្រហម តែម្នាក់ដែលអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា សម្រេចចោទប្រកាន់អំពី បទប្រល័យពូជសាសន៍ នៅក្នុងចន្លោះឆ្នាំពី ១៩៧៥ ដល់ ១៩៧៩ បានទទួលមរណភាព នៅខេត្តប៉ៃលិន ប្រទេសកម្ពុជា នៅថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៥ ។

អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា បានអះអាងថា លោកស្រីបានបាត់បង់ជីវិតនៅឯគេហដ្ឋានរបស់គាត់ ដោយសារតែគាំងបេះដូង។

ក្រោយទទួលមរណភាព អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចរំលត់បណ្តឹងអាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីប្រឆាំងរូបលោកស្រី ។

នៅមុនពេលទទួលមរណភាពលោកស្រីអៀង ធីរិទ្ធ ត្រូវបានតុលាការអះអាងថា លោកស្រីមានជំងឺវង្វេងវង្វាន់ស្មារតីកម្រិតធ្ងន់ធ្ងរ ហើយត្រូវបានសម្រេចដោះលែង ប៉ុន្តែបានដាក់នៅក្រោមការតាមដាន រហូតដល់លោកស្រីបានបាត់បង់ជីវិត។

លោកស្រី អៀង ធីរិទ្ធ កើតនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ១៩៣២ ជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៅអំឡុងពេលនៃរបបកម្ពុជា ប្រជាធិបតេយ្យ (ខ្មែរក្រហម)។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១០ លោកស្រីអៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០២ លើបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ នីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នៅតែត្រូវបន្តក្នុងឆ្នាំ ២០១២ បន្ទាប់ពីគាត់ត្រូវបានរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ ក្នុងការចូលរួមសវនាការ ដោយសារតែការវិវឌ្ឍនៃជំងឺវង្វេងវង្វាន់ បាត់ការចងចាំ ហើយគាត់ត្រូវបានដោះលែង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ លោក ស្រី អៀង ធីរិទ្ធ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់គាត់ស្លាប់៕

## រាជរដ្ឋាភិបាលកម្ពុជានឹងដាក់ទោសអ្នកដែលនិយាយបំភ្លៃរឿងបញ្ហាផែនទី

សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២១ ខែ សីហា បានដាក់ចេញនូវបទបញ្ជាឲ្យស្ថាប័នមានសមត្ថកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានវិធានការ ផ្លូវច្បាប់ភ្លាមៗចំពោះក្រុម ឬបុគ្គលណា ដែលនិយាយបំភ្លៃថា រាជរដ្ឋាភិបាលប្រើប្រាស់ផែនទីក្លែងក្លាយ ក្នុងការងារបោះបង្គោលព្រំដែន និងចំពោះការប្រមាថស្ថាប័នព្រះមហាក្សត្រ និងស្ថាប័នជាតិ ។

យោងទៅ តាមសេចក្តីប្រកាសព័ត៌មានរបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស របស់ទីស្តីការគណៈរដ្ឋមន្ត្រី នៅក្រោយកិច្ចប្រជុំគណៈរដ្ឋមន្ត្រី សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍រំឭក ថ្លែងអំណរគុណចំពោះលោក អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានប្រគល់ផែនទី UTM 1/100000 ឲ្យកម្ពុជាខ្ចីដើម្បីផ្ទៀងផ្ទាត់ ជាមួយផែនទីរបស់រាជ រដ្ឋាភិបាល ព្រមទាំងបានថ្លែងអំណរ- គុណ និងកោតសរសើរផងដែរ ដល់ភាគីពាក់ព័ន្ធទាំងអស់ដែលបានខិតខំធ្វើការងារ បញ្ជាក់ពីភាពត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការបោះបង្គោលព្រំដែន ជាមួយប្រទេសជិតខាង៕

*ដោយអរិយបុត្រ*

# របស់ប្លាស្ទិកតំបិុកតំប៉ុកតែមាន




*នំនិងអាហារសម្រន់មួយចំនួនវេចកញ្ចប់ផ្លាស្ទិក*

"*បើម៉្វៗ លុយហូរចូ*

*មិនដឹងជាមាន*

បើនិយាយអំពីប្លាស្ទិកនរណាៗក៏ដឹងអំពីផលប៉ះពាល់របស់វា ចំពោះសង្គម ចំពោះបរិស្ថាន សោភ័ណភាព និង ជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងដែរ ប៉ុន្តែភាគច្រើនគឺ ផ្តោតតែនៅលើថង់ប្លាស្ទិកប៉ុណ្ណោះ ខណៈដែលរបស់ប្លាស្ទិកឯទៀតពួកគេមិនបានរិះគិតដល់នោះទេ ។

មកដល់ពេលនេះ ដោយសារតែតម្រូវការនៃការប្រើប្រាស់ បើសិនជារាប់អំពីប្រភេទផលិតផលដែលប្រជាពលរដ្ឋប្រើប្រាស់ជាប្រចាំថ្ងៃនៅក្នុងជីវភាព គឺមានច្រើនមុខ ច្រើនយ៉ាងណាស់របស់វេចខ្ចប់ រហូតដល់របស់ទទួលទានដំណេក គឺសុទ្ធតែជាវត្ថុដែលផលិតពីសារធាតុ និង វត្ថុធាតុដើមដូចគ្នានឹងប្លាស្ទិកនេះផងដែរ ។

ក្រៅពីថង់ប្លាស្ទិកចេញ នៅជុំវិញរបស់ហូបចុកតែមួយមុខ អ្វីដែលប្រជាពលរដ្ឋទូទៅបានប្រើប្រាស់ នូវវត្ថុដែលធ្វើពីប្លាស្ទិក គឺមានជាច្រើនមុខ គឺរាប់ទាំងទុយយោ ឬបំពង់បឺតទឹក កញ្ចប់ស្នោ ឬកញ្ចប់ប្លាស្ទិកដាក់បាយ កញ្ចប់ប្លាស្ទិកដាក់ទឹកស៊ុប ធុងទឹកកកទាំងតូចទាំងធំ តុ កៅអី ...។

ជុំវិញបញ្ហានេះ លោក ជា បញ្ញាឫទ្ធិ ជាប្រជាពលរដ្ឋមួយរូប ដែលរស់នៅក្នុងសង្កាត់ស្ទឹងមានជ័យ បានឲ្យដឹងថា លោកបានដឹងអំពីគ្រោះថ្នាក់ នៃរបស់ដែលផលិតអំពីប្លាស្ទិច ចំពោះបរិស្ថាន និង ជីវភាពរស់នៅ ហើយក៏មានគំនិតចូលរួមចំណែក នៅក្នុងការកាត់បន្ថយការប្រើប្រាស់របស់ដែល ផលិតពីប្លាស្ទិកនេះផងដែរ ប៉ុន្តែនៅក្នុងជីវភាពជាក់ស្តែង គឺលោកបានទទួលស្គាល់អំពីការធ្វេសប្រហែសជាច្រើន នៅក្នុងការប្រើប្រាស់របស់ដែលផលិតពីប្លាស្ទិក ។

លោកបានបញ្ជាក់ថា "ឲ្យតែរបស់ដែលធ្វើពីប្លាស្ទិក គឺមានផលប៉ះពាល់ដូចគ្នាចំពោះបរិស្ថាន សុខភាព និង ជីវភាពរស់នៅ ទាំងខ្ញុំទាំងគេគឺផ្តោតតែលើរឿងថង់ ប៉ុន្តែភ្លេចគិតអារឿងបំពង់បឺត ប្រអប់ស្នោ ប្រអប់ស៊ុបអីនេះ"។

លោកបានបន្តទៀតថា "ពេលខ្ញុំទិញទំនិញ របស់វត្ថុមួយចំនួន បើមិនចាំបាច់ ខ្ញុំមិនដែល យកថង់ប្លាស្ទិកពីអ្នកលក់នោះទេ។ នេះជាទម្លាប់របស់ខ្ញុំ"។

លោកបានបន្តថា ក្រៅលោកអ្នកនៅក្នុងផ្ទះរបស់លោក ជាពិសេស គឺភរិយារបស់លោកក៏បានចូលរួមកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកនេះផងដែរ។

លោកបានបញ្ជាក់ថា "ពេលគាត់ទៅផ្សារទៅអី គឺកម្រឃើញមានថង់ច្រកត្រីថង់ច្រកបន្លែណាស់ គឺគាត់ប្រើតែកន្ត្រកប៉ុណ្ណោះ ប៉ុន្តែពួកយើងភ្លេចគិតពីរឿងបំពង់បឺតដែលធ្វើពីប្លាស្ទិកនេះដែរ"។

លោក ឈា តុលា ជាអ្នករត់ម៉ូតូឌុបមួយរូបបានឲ្យដឹងថា តាមបទពិសោធន៍របស់លោកកន្លងមក នៅពេលដែលលោកឌុបម៉ូយជាស្រ្តីមេផ្ទះ មកពីផ្សារ ឃើញថា មានអ្នកខ្លះ ជាពិសេសអ្នកដែលមានការយល់ដឹងអំពីផលប៉ះពាល់រឿងគ្រោះថ្នាក់ គឺព្យាយាមជៀសវាងមិនប្រើ ថង់ផ្លាស្ទិកច្រើន ដោយពួកគេងាកមកប្រើកន្ត្រកជំនួស ប៉ុន្តែបើនៅតាមកន្លែងលក់ភេសជ្ជៈតាមផ្លូវ ដូចជាកាហ្វេទឹកអំពៅ ទឹកសណ្តែងអី គឺដូចជាកើនឡើងទាំងអស់។

លោកបានបញ្ជាក់ថា "កន្លែងលក់កាហ្វេ លក់ទឹកសណ្តែក លក់ទឹកអំពៅតាមចិញ្ចើមផ្លូវឥឡូវ គឺភាគច្រើនលែងមានកែវ គឺសុទ្ធតែប្លាស្ទិក"។ លោកបាននិយាយបន្ថែមទៀតថា ឥឡូវនេះកន្លែងដែលមានកែវ មានអីត្រឹមត្រូវ គឺមានតែហាងប៉ុណ្ណោះ បើតាមចិញ្ចើមផ្លូវ គឺមានតែកែវប្លាស្ទិក ។

លោកបានបញ្ជាក់ទៀតថា "នៅតាមកន្លែងលក់បាយ លក់ សម្លអី នៅពេលនេះ កន្លែងខ្លះរកតែកែវ ឬពែងផឹកទឹកក៏មិនមានដែរ គឺសុទ្ធតែរបស់ប្លាស្ទិកទាំងអស់ "។

រហូតមកដល់ពេលនេះ តម្រូវការនៃការប្រើប្រាស់ផលិតផលប្លាស្ទិក នៅក្នុងប្រទេស គឺហាក់ដូចជាមានកំណើនកើនឡើង ប៉ុន្តែនៅកម្ពុជា ហាក់គ្មានការសិក្សា អំពីបរិមាណច្បាស់លាស់ណាមួយ ដែលបានសិក្សាអំពីតម្រូវការនេះឲ្យច្បាស់លាស់នៅឡើយទេ ដោយប្រជាពលរដ្ឋម្នាក់ៗ គឺបានដឹងបានយល់អំពីផលប៉ះពាល់នេះ តែតាមរយៈស្ប៉តអប់រំបរិស្ថាន ការបណ្តុះបណ្តាល ការផ្សព្វផ្សាយមួយចំនួនតូចប៉ុណ្ណោះ ។

អ្នកនាំសារបានព្យាយាម ស្វែងរកតួរលេខពិតប្រាកដអំពីចំនួនបរិមាណ នៃការផលិត និងការនាំចូលនូវផលិតផលពីប្លាស្ទិកមកបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គឺមកដល់ពេលនេះ រកមិនបានទាល់តែសោះ ដោយគ្រាន់តែដឹងថា នៅកម្ពុជាក្រៅពីនាំចូល នូវវត្ថុប្រើប្រាស់ប្លាស្ទិកពីប្រទេសជិតខាង គឺកម្ពុជាក៏មានរោងចក្រផលិត ផលិតផលប្លាស្ទិកដូចជាថង់នេះផងដែរ ។

ម្ចាស់ហាងអាហារមួយរូប នៅម្តុំផ្សារកណ្តាល បានឲ្យដឹងថា ជាមធ្យមនៅក្នុងមួយថ្ងៃ គាត់ប្រើប្រាស់ថង់ប្លាស្ទិកប្រមាណជា កន្លះគីឡូក្រាម ប្រអប់ស្នោប្រមាណជាជាង ១០០ទៅ ២០០ ប្រអប់ នៅក្នុងមួយថ្ងៃ ក្រៅពីនោះ នៅមានបំពង់បឺត ស្លាបព្រា កែវជ័រមួយចំនួនទៀត ។

លោកស្រី បានឲ្យដឹងដោយខ្លីថា លោកស្រីបានដឹងអំពីផលប៉ះពាល់ និងភាពគ្រោះថ្នាក់ខ្លះៗ អំពីរបស់ប្លាស្ទិកទាំងនេះ ប៉ុន្តែធ្វើម៉េច បើនេះគឺជាតម្រូវការអតិថិជន។ លោកស្រី បានបន្តថា នៅក្នុងមួយថ្ងៃ មានអតិថិជន ប្រមាណជាពី ៦០ទៅ ៧០ភាគរយ ដែលត្រូវការវេចខ្ចប់ ខណៈដែលអតិថិជន ដែលមករកទទួលទានដល់កន្លែង គឺមានពី ៣០ទៅ ៤០ភាគរយប៉ុណ្ណោះ ។

លោកស្រីបានបញ្ជាក់ថា "សម័យនេះ បើយើងលក់បាយខ្ចប់ស្លឹកឈូកទៀតនរណាទិញ ចុះសម្ល បើមិនដាក់ថង់បានអីដាក់? ដាក់ស្លឹកឈូកកើតឬ"?

ជុំវិញ បញ្ហាកាកសំណល់ប្លាស្ទិកនេះ កម្មករបាលូមួយរូប ឈ្មោះ តា យឹម បានអះអាងថា តាមដែលលោកបានជួបប្រទះ លូភាគច្រើនស្ទះ គឺដោយសារភក់ដី និងប្លាស្ទិក ។

លោកបានបញ្ជាក់ថា "ទីណាក៏ដូចជាទីណាដែរឲ្យតែស្ទះ ពេលបារទៅ គឺឃើញសុទ្ធតែប្លាស្ទិក គឺមានថង់រហូតដល់កំប៉ុង សំបកដប ហើយបើជិតកន្លែងលក់បាយ លក់ទឹកអំពៅអីគឺសុទ្ធតែទុយយោបឺត"។

កន្លងមកក្រសួងបរិស្ថានក្តី ក្រសួងទេសចរណ៍ក្តី គឺកំពុងតែយកចិត្តទុកដាក់ណាស់ លើករណីសំណល់ប្លាស្ទិក

# ឥទ្ធិពលដល់ជីវិត




បក់នៅក្នុងតូបចាប់ហួយ។ រូបថតៈ រឿន ស្រីម៉ាច

*លដូចជាថង់ប្លាស្ទិក*
*យ៉ាងណាទេ។"*

នេះ រហូតដល់កំណត់ជាផែនការមួយចំនួន ឈានទៅលុបចោលការប្រើប្រាស់ថង់ប្លាស្ទិក នៅតាមកន្លែងមួយចំនួនដូចជា នៅតាមផ្សារទំនើបជាដើម ប៉ុន្តែមកដល់ពេលនេះ អ្វីៗហាក់ដូចជានៅមិនទាន់មានការរីកចម្រើនសោះ ហើយកំណើន នៃការប្រើប្រាស់វត្ថុធ្វើពីប្លាស្ទិក គឺរឹតតែសំខាន់ សម្រាប់ជីវភាពរបស់ប្រជាពលរដ្ឋសាមញ្ញទូទៅ ។

លោក បញ្ញាឫទ្ធិ បាននិយាយថា ជារៀងរាល់ថ្ងៃ ផ្ទះណាក៏ដូចជា ផ្ទះណាដែរ គឺថង់ផ្លាស្ទិកហូរចូលផ្ទះរាល់ថ្ងៃយ៉ាងហោចណាស់ ក៏ពីរទៅបីថង់ដែរនៅក្នុងមួយថ្ងៃ ។

លោកបានបញ្ជាក់ថា "រាល់ថ្ងៃខ្ញុំតែងនិយាយលេងជាមួយប្រពន្ធថា បើម៉ែៗលុយហូរចូលដូចជា ថង់ប្លាស្ទិក មិនដឹងជាមានយ៉ាងណាទេ "។

មន្ត្រីនៅមន្ទីរបរិស្ថានរាជធានីភ្នំពេញមួយរូប បានមានប្រសាសន៍នៅក្នុងលក្ខខណ្ឌ មិនបញ្ចេញអត្តសញ្ញាណថា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ នៅពេលបច្ចុប្បន្ននេះ គឺដូចជារស់នៅក្នុងពិភពប្លាស្ទិកដូច្នេះដែរ គឺងាកទៅណាក៏ឃើញសុទ្ធតែរបស់បាស្ទិកទាំងអស់ ដូច្នេះសង្គមយើងនាពេលបច្ចុប្បន្ននេះ វាពិបាក មិនប្រើប្រាស់របស់ប្លាស្ទិកនេះណាស់ ពោលគឺថា បើនិយាយអំពីការជៀស គឺជៀសមិនរួច តែម្តងប៉ុន្តែទាំងអស់គ្នា ត្រូវតែមាននិន្នាការកាត់បន្ថយ ។

លោកបានបញ្ជាក់ថា "សម័យនេះបើយើងមិនប្រើរបស់ប្លាស្ទិក គឺពិបាក ប៉ុន្តែអ្វីដែលយើងអាច ចៀសវាងបាន គឺគួរតែចៀសទៅ ប៉ុន្តែមានឯណា អ្នកខ្លះពេលផឹកនៅខាងក្រៅផ្ទះអី មិនមែនប្រើតែបំពង់បឺតមួយទេ គឺប្រើដល់ទៅពីរ "។

លោកបាននិយាយថា រឿងអនុវត្តការកាត់បន្ថយការប្រើប្រាស់ វត្ថុផលិតពីថង់ប្លាស្ទិកនេះ គឺអាចនឹងអនុវត្តបានលុះត្រាតែមាន ការចូលរួមទាំងអស់គ្នាយល់ដឹងទាំងអស់គ្នា ហើយអនុវត្តទាំងអស់គ្នា ។

លោកបានបន្តថា ដាក់ស្តែងរឿងបំពង់បឺតនេះ ពីមុនមកមានអ្នកណាទៅផឹកកាហ្វេដាក់បំពង់បឺត គឺផឹកតែនឹងកែវ ប៉ុន្តែឥឡូវនេះ បើទៅហាងណាអត់មានបំពង់បឺត មនុស្សភាគច្រើនដែលជាអតិថិជន គិតថា វាអត់អនាម័យហាងនេះហាងនោះអត់ទាន់សម័យ ។

លោកបានបន្តថា នេះគឺជាការយល់ដឹងរបស់មនុស្សសម័យនេះ ដោយសារតែការបារម្ភអំពីសុវត្ថិភាព និងបញ្ហាសុខភាពផ្ទាល់ខ្លួន ប៉ុន្តែយើងអាចនឹងកាត់បន្ថយបាន ប្រសិនបើយើង ងាកមករកអ្វីដែលធ្លាប់ពីមុន ហើយដើម្បីកុំឲ្យអតិថិជនគេរអ៊ូរឿងអនាម័យ បណ្តាហាងហូបចុកទាំងនេះ គួរណាស់តែភ្ជាក់រលឹករឿងអនាម័យ ។

លោកបានបញ្ជាក់ថា"បញ្ហាអនាម័យនេះ មិនមែនត្រឹមតែ ចំអិនឆ្អិននៅផ្ទះបាយនោះទេ ។ អនាម័យវាកើតបាន គឺលុះត្រាតែស្អាតតាំងពីចាន ស្លាបព្រាកែវ ដូច្នេះបើយើងអាចធ្វើបានបែបនេះ ប្រហែលជា អតិថិជន ក៏មិនទារបំពង់បឺតដែរ" ៕

*ដោយអរិយបុត្រ*

## ផលប៉ះពាល់នៃសំណល់ប្លាស្ទិក

វាមិនមែនជារឿងថ្មីទេ នៅពេលដែលនិយាយអំពីផលប៉ះពាល់ នៃសំណល់ប្លាស្ទិក ប៉ុន្តែអ្វីដែលយើងធ្វើ គឺដើម្បីរំឭកសារ និងពញាក់អារម្មណ៍ជាថ្មី ជូនសាធារណៈជនទាំងអស់បានជ្រាប អំពីគ្រោះថ្នាក់ នៃកាកសំណល់នេះ ។

តាមឯកសារ បានឲ្យដឹងថា វត្ថុដែលផលិតអំពីប្លាស្ទិក គឺត្រូវការពេលវេលារាប់រយឆ្នាំ ដើម្បីបំបែកធាតុ ដូច្នេះវាគ្រោះថ្នាក់ សម្រាប់ដីពោលគឺធ្វើឲ្យខូចគុណភាពដី ប្រសិនបើនៅជនបទ ប៉ុន្តែសម្រាប់នៅទីក្រុង គឺងាយស្រួលបង្ករការកកស្ទះ ងាយស្រួលអណ្តែត និងហូរចូលទៅក្នុងបណ្តាញប្រព័ន្ធលូនានា ។

ឯកសារ បានបញ្ជាក់ថា ត្រឹមតែថង់ប្លាស្ទិកមួយទេ គឺត្រូវប្រើពេលវេលារហូតដល់ទៅ ប្រមាណជា ៥០០ឆ្នាំ ទើបរលាយ បើកប់នៅក្នុងដី ប៉ុន្តែបើដុត គឺវានឹងប៉ះពាល់ ដល់បរិស្ថាន និងសុខភាព ។

ឯកសារ បានឲ្យដឹងថា នៅពេលដែលមនុស្សស្រូបខ្យល់ ដែលមានសារធាតុដែលបង្កឡើង ពីការដុតសំណល់ប្លាស្ទិក គឺអាចប៉ះពាល់ដល់សួត ក្រពះ និងភ្នែក ជាពិសេសគឺសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ ៕

## សកម្មភាពខ្លះ ដែលគួរយកចិត្តទុកដាក់ និងចូលរួមកាត់បន្ថយសំរាមប្លាស្ទិក

ដើម្បីព្យាយាម និងចូលរួមកាត់បន្ថយសំរាមប្លាស្ទិក នៅក្នុងប្រទេសសកម្មភាព ដែលសកម្មជនបរិស្ថានបានផ្តល់ដំបូន្មានគឺថា ព្យាយាមដាក់កំរិតនៅក្នុងការនាំយកនូវផលិតផលប្លាស្ទិកចូលផ្ទះឲ្យតិចបំផុត។

លោក ជា បញ្ញាឫទ្ធិ ជាប្រជាពលរដ្ឋមួយរូប ដែលរស់នៅក្នុងសង្កាត់ស្ទឹងមានជ័យ បានចែករំលែក បទពិសោធន៍ ដែលអនុវត្តនៅក្នុងគ្រួសាររបស់លោកថា នៅពេលទិញទំនិញ បើសិនជាអាច សុំកុំទទួលយកថង់ពីអ្នកលក់ ព្យាយាមប្រើប្រាស់នូវរបស់ដែលអាចប្រើឡើងវិញបាន ចៀសវាងប្រើម្តងបោះចោល។ ពេលជូនភរិយាទៅផ្សារ ចូលរួមរំឭករឿងកន្ត្រក ឬថង់ក្រណាត់ សម្រាប់ពេលវេចខ្ចប់ម្ហូបមកផ្ទះ ។

លោកបានបន្តទៀតថា ភរិយារបស់លោក ដែលជាអ្នកយល់ដឹងអំពីបរិស្ថានមួយរូប គឺពេលទិញ ម្រេចទិញ ខ្ទឹម ទិញ គ្រឿងទេសបន្តិចបន្តួចសម្រាប់ស្ល គឺកម្រទិញរបស់ដែលវេចខ្ចប់ដោយថង់ ប្លាស្ទិក ណាស់។

លោកបានបន្តថា ពេលដែលដើរលេងទៅទីណាឆ្ងាយ គឺគ្រួសាររបស់លោកកម្រវេចខ្ចប់ម្ហូប ជាមួយនឹងវត្ថុធ្វើពីប្លាស្ទិក ឬស្នោណាស់ គឺភាគច្រើនប្រើចាន ឆ្នាំង ដែលអាចលាងសំអាត និង ប្រើឡើងវិញបាន ៕

# ទិវាយុវជនឡាវនិង




រូបថត: ធីរិទ្ធ



រូបថត: ធីរិទ្ធ



រូបថត: សុវណ្ណា



រូបថត: សុវណ្ណា

សម្លេងច្រៀងទ្រហឹងអឺងកង ក្នុងសាលធំមួយ លាយឡំជា២ភាសាបញ្ចូលគ្នាបង្កើតជាចំណីអារម្មណ៍មួយបែបផ្សេងសម្រាប់ យុវជន-យុវនារី ប្រមាណជិត ៣០០នាក់ ដែលកំពុងបង្ហាញកាយវិការជាជួរៗតាមទំនុកចម្រៀង។

នេះជាទិវាយុវជន ឡាវ-កម្ពុជា ជាលើកទី១ ដែលរៀបចំឡើង ដោយក្រុមប្រឹក្សាលោកអភិបាល ឡាវ-កម្ពុជា ធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ពីថ្ងៃទី ១០-១៦ សីហាកន្លងទៅ។ ជំនួបនេះបានធ្វើឡើងជាដំណាក់ៗ ដែលធ្វើឲ្យយុវជនអាចស្វែងយល់ពីព្រះសហគមន៍ មរណសាក្សីរបស់ប្រទេសកម្ពុជា និងឡាវ និងភាតរភាព របស់ព្រះសហគមន៍ទាំងពីរប្រទេស។

" ពេលខ្ញុំ បានចូលរួមក្នុងទិវាយុវជនកម្ពុជា-ឡាវនេះ ខ្ញុំបានទទួលបទពិសោធន៍ថ្មីៗរបស់យុវជនឡាវ ក៏ដូចជាសកម្មភាពរបស់យុវជនកម្ពុជាផងដែរ ។ ខ្ញុំស្គាល់ព្រះសហគមន៍ បានច្រើនជាងមុន ទាំងមរណសាក្សីប្រទេសយើង និងប្រទេសគេ"។ នេះជាសំដីរបស់យុវនារីកម្ពុជាម្នាក់ឈ្មោះ វង្ស វល័ក្ខណ៍។

លោកផុន សុផល ជាប្រធានការិយាល័យ យុវជនជំទង់ និងកុមារ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា ការរៀបចំកម្មវិធីនេះឡើង គឺដើម្បីឲ្យយុវជនកម្ពុជា និងឡាវបានស្គាល់ និងចែករំលែកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមកអំពីព្រះសហគមន៍ និងមរណសាក្សី។

លោក សុផល បានបន្តថា ក្នុងកម្មវិធីនោះដែរ គឺដើម្បីពង្រឹងជំនឿឲ្យយុវជនមានភាពរឹងមាំនៅក្នុងជីវិត ជាគ្រីស្តបរិស័ទ ដោយយើងមានកម្មវិធីជាច្រើនដូចជា ពិធីអធិដ្ឋាន និងអភិបូជារួមគ្នា ការរិះគិត អំពីជីវិតរបស់យើងជាមួយព្រះយេស៊ូ និងបង្ហាញជំនឿរបស់យើងស្របគោលតាមលទ្ធិព្រះសហគមន៍ និងតាមបរិបទអាស៊ាន។

លោក សុផល បានបញ្ជាក់ទៀតថា "ដូច្នេះក្នុងនាមយើង ជាយុវជន កម្ពុជាឡាវ ត្រូវបង្ហាញមុខព្រះយេស៊ូយ៉ាងម៉េចដល់សង្គមអាស៊ាន និងបង្ហាញពីសកម្មភាព របស់យើងក្នុងបរិបទអាស៊ានយ៉ាងដូចម្តេច?"

ទិវាយុវជនកម្ពុជា-ឡាវ បានធ្វើឡើងមួយសប្តាហ៍ ដោយផ្តើមចេញពីព្រះសហគមន៍ភូមិភាគកំពង់ចាម ទៅកាន់ទឹកដីមរណសាក្សីកម្ពុជា នៅតាំងគោក ទៅកាន់ព្រះសហគមន៍ ភូមិភាគភ្នំពេញ និង ទៅកាន់ព្រះសហគមន៍ភូមិភាគបាត់ដំបង។ ក្នុងនោះយុវជនទាំងអស់ ដែលមានឡាវចំនួន៨៦នាក់ និងខ្មែរប្រមាណ ២០០នាក់ ត្រូវរួមគ្នាជាក្រុមតូច ដើម្បីចែករំលែកបទពិសោធន៍ ធ្វើការរួមគ្នាជាក្រុម និង ធ្វើដំណើរទៅតាមព្រះសហគមន៍នីមួយៗ ដើម្បីស្វែងយល់ពីព្រះសហគមន៍។

ការចុះទស្សនកិច្ចនៅតាមតំបន់នានា ដើម្បីមើលពីស្ថានភាពទូទៅ នៅក្នុងប្រទេសកម្ពុជា និងនៅតាមព្រះសហគមន៍ បានធ្វើឲ្យយុវជន សេងចាន់ ស៊ូវ៉ាន់ថន (Sengchanh Souvanthone) មកពីប្រទេសឡាវ យល់ឃើញថា ជីវិតត្រូវតែតស៊ូ និងត្រូវពឹងផ្អែកលើព្រះហស្តរបស់ព្រះជាម្ចាស់។ ស៊ូវ៉ាន់ថនបន្ថែមថា "ខ្ញុំរីករាយណាស់ ដែលបានឃើញព្រះសហគមន៍ ទៅជាឧបករណ៍មួយ ដើម្បីជួយអ្នកតូចតាច ជាពិសេសអ្នកក្រីក្រ អ្នកជំងឺ។ កិច្ចការនេះបង្ហាញថា ព្រះជាម្ចាស់យកចិត្តទុកដាក់ ចំពោះមនុស្សគ្រប់គ្នា"។

វី សំណាង មកពីព្រះសហគមន៍តួតាំង បាននិយាយថា ទិវានេះបានផ្តល់អត្ថប្រយោជន៍ជាច្រើន ឲ្យលោកយល់ពីរបៀបបង្កើតភាតរភាព រវាងបងប្អូនឯទៀតៗ ដោយមិនចាំបាច់ពឹងផ្អែកទៅលើភាសានិយាយតែប៉ុណ្ណោះទេ។ លោកយល់ឃើញថា សំខាន់គឺយើងមានភាសានៃសេចក្តីស្រឡាញ់ និងចេះសាមគ្គីគ្នាដោយជួយគ្នាទៅវិញទៅមក និង ចេះលើកលែងទោសឲ្យគ្នា។

សំណាងបន្ថែមថា លើសពីនេះទៅទៀត កម្មវិធីនេះ បានបណ្តុះចិត្តគំនិតរបស់គាត់ ឲ្យកាន់តែស្រឡាញ់ និងមានជំនឿលើព្រះជាម្ចាស់បន្ថែមទៀត ទោះបីជាស្ថិតនៅកាលៈទេសៈណាក៏ដោយ ។ សំណាង "ព្រោះយើងមានមរណសាក្សីជាគំរូនៃជំនឿ និង ដោយពឹងផ្អែកលើសេចក្តីស្រឡាញ់ដ៏ធំធេង របស់ព្រះជាម្ចាស់"។

យុវជននេះបន្ថែមថា "ព្រះជាម្ចាស់មានតែមួយ ជំនឿមានតែមួយ ហើយយើងជាគ្រួសារតែមួយ ក្នុងអង្គព្រះគ្រីស្តដូចនេះខ្ញុំមិនខ្លាចអ្វីឡើយ និងទុកចិត្តលើព្រះជាម្ចាស់ ព្រោះទ្រង់ជាកម្លាំងរបស់ខ្ញុំ"។

នៅជាមួយយុវជនឯទៀត ក្នុងសាលប្រជុំធំ ប៉ាវ (Bao) មកពីប្រទេសឡាវ បាននិយាយថា "អ្វីដែលខ្ញុំបានរៀនក្នុង

# កម្ពុជាលើកទីមួយ

កម្មវិធីនេះគឺយើង(យុវជនកម្ពុជា-ឡាវ) ប្រៀបដូចជាផ្លូងតែមួយ និងជាបងប្អូន"។

ប៉ាវ បញ្ជាក់ថា "បន្ទាប់ពីកម្មវិធីនេះទៅ ខ្ញុំនឹងត្រឡប់ទៅប្រទេសខ្ញុំវិញ ហើយនឹងយកបទពិសោធន៍ ដែលទទួលបានក្នុងកម្មវិធីនេះ ទៅធ្វើកម្មវិធីសម្រាប់ភូមិភាគរបស់ខ្ញុំដែរ"។

ជាមួយគ្នានេះ យុវជនទាំងអស់ក៏មានពេលវេលា ដើម្បីយល់ដឹងបន្ថែមអំពីសង្គម អាស៊ានសម្រាប់ឆ្នាំ ២០១៥ និងទស្សនៈសាសនា រួមមាន ព្រះពុទ្ធសាសនា និងគ្រីស្តសាសនាផងដែរ។

លោកអភិបាលអូលីវីយេ ឝ្មីតអីស្លែរ ជាប្រធានក្រុមប្រឹក្សាលោកអភិបាលឡាវកម្ពុជា និងជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ មានប្រសាសន៍ថា "ខ្ញុំសប្បាយចិត្តដោយសារពេញមួយអាទិត្យយើងបានជោគជ័យរួមជាមួយគ្នាជាក្រុមគ្រួសារតែមួយ។ នៅក្នុងព្រះសហគមន៍(យើង)ជាបងប្អូនដែលចេះស្រឡាញ់គ្នាពិតមែន។ ទោះបីយើងនិយាយភាសាខុសៗគ្នា ប៉ុន្តែយើងឃើញថា ចិត្តរបស់យើងបានចូលគ្នាយ៉ាងជ្រៅ ទាំងនៅក្នុងជំនឿ ទាំងនៅក្នុងមិត្តភាព ទាំងនៅក្នុងភាតរភាព"។

លោកអភិបាលបន្តទៀតថា "នេះជាកម្លាំងមួយ ដើម្បីឲ្យជំនឿរបស់យើងបន្តធ្វើសក្ខីភាពតាមកន្លែងដែលយើងនៅជាប្រចាំ។ ដូច្នេះខ្ញុំអរព្រះគុណព្រះជាម្ចាស់ ហើយខ្ញុំសង្ឃឹមយើងបន្តដោយបង្ហាញថា ប្រទេសយើងទាំងពីរជាបងប្អូន មិនមែនតែលោកអភិបាល ដែលជួបជុំជាមួយគ្នាតែគ្រីស្តបរិស័ទ ដែលជួបជុំគ្នានៅទីនេះ។ ជាឱកាសមួយដើម្បីឲ្យជំនឿ របស់យើងរឹងមាំ និងមានសង្ឃឹមជានិច្ចទោះបីយើងជួបទុក្ខលំបាកក្នុងជីវិត តែយើងដឹងថា យើងមានបងប្អូន ដែលស្រឡាញ់យើង លើកទឹកចិត្តយើង ដើម្បីបន្តដំណើរជាមួយព្រះអង្គ និងប្រកាសដំណឹងល្អរបស់ព្រះយេស៊ូផង"។

ក្នុងទិវាយុវជនកម្ពុជាឡាវនេះ មានការចូលរួមជា អធិបតីភាពពីលោកអភិបាលព្រះសហគមន៍កាតូលិកនៃប្រទេសកម្ពុជាទាំងបីភូមិភាគ និងលោកអភិបាលពីប្រទេសឡាវ រួមមានលោកអភិបាលអូលីវីយេ ឝ្មីតអីស្លែរ លោកអភិបាលគីគេ ហ្វីការេដូ លោកអភិបាលអន់តូនីសាមីស៊ូសៃរាជ្យ និងលោកអភិបាលលូវីស ម៉ារីលីង ម៉ងខាណេខូន។

មុនពេលបិទទិវាយុវជន កម្ពុជា-ឡាវនេះ លោកអភិបាលអូលីវីយេ បាន ប្រកាសថា ទិវាយុវជនកម្ពុជាឡាវ នឹងមានជាលើកទី២នៅលើទឹកដី នៃប្រទេសឡាវ ក្នុងឆ្នាំ២០១៨ខាងមុខនេះ។

**សេចក្តីថ្លែងការរួមគ្នា របស់ក្រុមយុវជនកាតូលិកកម្ពុជា - ឡាវ មានបួនចំណុចសំខាន់ៗគឺ៖**

១). **ជំនឿ ៖** យុវជនយុវនារីកាតូលិកកម្ពុជាឡាវ បន្តសន្ទនាផ្ទាល់ ជាមួយព្រះយេស៊ូគ្រីស្ត ក្នុងជីវិតរស់នៅប្រចាំថ្ងៃគ្រប់ទីកន្លែង បន្តយកចិត្តទុកដាក់ថែរក្សាពង្រឹងជំនឿ និងធ្វើជាសាក្សីនៃជំនឿដល់យុវជនឯទៀតៗ និងបន្តចូលរួមកសាងព្រះរាជរបស់ព្រះជាម្ចាស់ តាមសកម្មភាពមេត្តាករុណា ជាពិសេសចំពោះអ្នកតូចតាច ឲ្យបានចូលរួមក្នុងសង្គម និងការប្រកាស ដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ត។

២). **វប្បធម៌ និងអត្តសញ្ញាណ ៖** យុវជនយុវនារីកាតូលិក កម្ពុជា-ឡាវ នឹងបន្តសន្ទនាផ្ទាល់រវាងគ្នានិងគ្នា និងចែករំលែកវប្បធម៌ប្រពៃណី ព្រមទាំងពង្រឹងនូវភាតរភាពជាបងប្អូន ក្នុងសេចក្តីស្រឡាញ់ និងធ្វើជាស្ពាន ដើម្បីបង្កើតទំនាក់ទំនងដោយយល់ចិត្តគ្នា និងស្ថិតក្នុងអត្តសញ្ញាណផ្ទាល់ខ្លួន។

៣). **អាស៊ានតាមការសន្ទនា អន្តរសាសនា ៖** យុវជន-យុវនារី កាតូលិកកម្ពុជា-ឡាវ ប្តេជ្ញាតាំងចិត្ត បន្តការសន្ទនា ជាមួយសាសនាដទៃ ដើម្បីចូលរួមកសាងសង្គមអាស៊ាន តាមបែបផ្លូវវិញ្ញាណ ជាពិសេស ជួយឲ្យអាស៊ានមានភាតរភាព សន្តិភាព និងសេរីភាព ដែលអាចអនុញ្ញាតឲ្យសម្លេង របស់ជនក្រីក្រ អ្នកតូចតាច មានក្នុងការកសាងសង្គមអាស៊ាន។

៤). **ចូលរួមក្នុងសង្គម ៖** តាមរយៈការប្រៀនប្រដៅ នៃលទ្ធិព្រះសហគមន៍កាតូលិក យុវជនយុវនារីកម្ពុជា-ឡាវតាំងចិត្តសម្តែងនូវភាតរភាព គោរពភាពថ្លៃថ្នូររបស់មនុស្សទាំងអស់ ដោយយកផលប្រយោជន៍រួមជាមូលដ្ឋានគ្រឹះ ក្នុងការសម្រេចចិត្ត និងបន្តពង្រឹងនូវការការពារថែរក្សាធម្មជាតិ ដែលជាទ្រព្យសម្បត្តិរួមរបស់មនុស្ស៕

*ដោយ កញ្ញានិងដាលីស*



*រូបថត: សុវណ្ណា*



*រូបថត: កញ្ញា*



*រូបថត: កញ្ញា*



*រូបថត: សុវណ្ណា*

# សិស្សនៃព្រះសហគមន៍តាហែនជាប់បាក់ឌុប ៧ នាក់

លទ្ធផល នៃការប្រឡងសញ្ញាបត្រទុតិយភូមិឆ្នាំ២០១៥នេះ សិស្សរបស់ព្រះសហគមន៍កាតូលិកតាហែន នៃខេត្តបាត់ដំបង បានជាប់ចំនួន៧នាក់ ក្នុងចំណោមសិស្ស ១១នាក់ ដែលទទួលអាហាររូបករណ៍ ពីព្រះសហគមន៍។

កញ្ញា សៀ សៀក ជាសមាជិកគណៈកម្មការ នៃព្រះសហគមន៍កាតូលិកតាហែនបានឲ្យដឹងថា ៖ ក្នុងចំណោមសិស្ស ដែលបានទទួលអាហារូបករណ៍ របស់ព្រះសហគមន៍សរុបទាំងអស់ ៦១នាក់ ហើយមាន ១១នាក់ ដែលបានចូលរួមប្រលងបាក់ឌុបនាឆ្នាំនេះ ជាប់តែ៧នាក់ទេ។ ប៉ុន្តែសម្រាប់លទ្ធផលឆ្នាំនេះ គឺមានភាពល្អប្រសើរជាងឆ្នាំកន្លងទៅ ។

កញ្ញាបានបន្តថា៖ លោកអភិបាល ហ្វីការដូ អេនរីគេ អភិបាលព្រះសហគមន៍ កាតូលិកភូមិភាគបាត់ដំបង បានគាំទ្រលើគម្រោងអាហារូបករណ៍សិស្សក្រីក្រ សម្រាប់មណ្ឌលសិស្ស នៃព្រះសហគមន៍តាហែនយើងនេះ។ ហើយសិស្ស ដែលបានប្រឡងជាប់ នឹងទទួលបានអាហារូបករណ៍ បន្តទៅកាន់សកលវិទ្យាល័យនាក្រុងបាត់ដំបង។

មណ្ឌលសិស្ស នៃព្រះសហគមន៍តាហែន គឺមានទទួលសិស្សឲ្យស្នាក់នៅ រៀនសូត្រតាំងពីសិស្ស ថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់សកលវិទ្យាល័យ ដែលសិស្សទាំងនោះ ត្រូវបានជ្រើសរើសពីគ្រួសារក្រីក្រ សិស្សដែលមានផ្ទះនៅឆ្ងាយពីសាលា កុមារកំព្រាឪពុកម្ដាយនិងគ្មានឱកាសរៀនសូត្រ ។

*ដោយឡុងសម្ផស្ស*

# កម្មវិធីបិទវគ្គសិក្សានៃវិទ្យាល័យដុនបូស្កូបាត់ដំបង




វិទ្យាល័យដុនបូស្កូបាត់ដំបង បានរៀប ចំកម្មវិធីបិទវគ្គសិក្សា ២០១៤-២០១៥ ក្រោមអធិបតីភាពរបស់ លោកបូជាចារ្យឡេអូណាត អូល្វ៉ា ជាអធិកាបតី នៃវិទ្យាល័យដុនបូស្កូ និងលោកគីគេ ហ្វីការដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ដែលមានសិស្សានុសិស្ស និងអាណាព្យាបាលចូលរួម មប្រមាណ៩០០នាក់ កាលពីថ្ងៃទី ២១ សីហាកន្លងទៅ នៅភូមិអណ្ដូងចេញ ស្រុកអូរចារ ខេត្តបាត់ដំបង។

លោកហម តឿ ជានាយកវិទ្យាល័យដុនបូស្កូបានមានប្រសាសន៍ថា គោលដៅសំខាន់របស់សាលាយើង គឺជួយដល់កុមារក្រីក្រ កុមារធ្វើការនៅឡជដ្ឋ កុមារកំព្រាឬត្រូវបានបោះបង់ចោល និងកុមារដែលគ្មានឱកាសទទួល បានការអប់រំ។ គឺយើងចង់កសាងធនធាន និងពង្រឹងគុណភាពនៃមនុស្សជំនាន់ក្រោយ ដើម្បីអនាគតប្រសើរ។

លោកហម តឿ បន្តថា "បន្ទាប់ពីសិស្សបានបញ្ចប់ការសិក្សាថ្នាក់ទី ១២ នៅសាលានេះ សិស្សានុសិស្សអាចបន្តរៀនជំនាញខ្លីនៅសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូនៅសាឡាបាឡាត់"។

លោកតឿបន្ថែមថា ជំនាញគឺជាអនាគតការងារមួយ ដែលសិស្សទាំងអស់ត្រូវទទួលបាន។ យើងក៏លើកទឹកចិត្តសិស្សរបស់យើង ឲ្យចេះរៀបចំខ្លួនមានសណ្ដាប់ធ្នាប់ មានសេចក្ដីស្រឡាញ់ក្នុងខ្លួន និងក្លាយជាសិស្សល្អ ពលរដ្ឋល្អសម្រាប់សង្គមជាតិ។ យើងក៏ណែនាំពួកគេ ឲ្យស្គាល់ពីស្មារតីរបស់ដុនបូស្កូ ដែលជាអ្នកបង្កើតឲ្យយុវជនមានឱកាសសិក្សា គឺឲ្យពួកគេយល់ថាគេជាគ្រួសាររបស់ដុនបូស្កូ។

ក្នុងកម្មវិធីបិទវគ្គសិក្សាឆ្នាំ ២០១៤-២០១៥នេះ គណៈអធិបតីបានប្រគល់វិញ្ញាបនបត្របញ្ចប់ការសិក្សា និងបណ្ណសរសើរដល់សិស្សថ្នាក់ ទី៦ និងទី៩ផងដែរ។

វិទ្យាល័យដុនបូស្កូ គឺជាសាលាគ្រប់គ្រង ដោយក្រុមបព្វជិតកាតូលិកសាលេស៊ានដុនបូស្កូ ត្រូវបានបើកឲ្យប្រើជាផ្លូវការកាលពីថ្ងៃទី ២០ មីនា ២០១៣កន្លងទៅ។

វិទ្យាល័យដុនបូស្កូ មានបង្រៀនពីថ្នាក់បឋមសិក្សា រហូតដល់វិទ្យាល័យ ដែលមានសិស្សសរុប ប្រមាណ៦០០នាក់ ក្នុងនោះថ្នាក់បឋមសិក្សា មានពីថ្នាក់ទី១ដល់ទី៦ និងវិទ្យាល័យមានពីថ្នាក់ទី៧ហូតដល់ថ្នាក់ទី១១ សម្រាប់ឆ្នាំសិក្សា២០១៥-២០១៦នេះ។

# សិស្សនៃមណ្ឌលណូប៊ីលី ប្រឡងជាប់ទុតិយភូមិជិត៩០%

មណ្ឌលសិស្សណូប៊ីលី នៃព្រះវិហារសន្ត ហ្វ្រង់ស្វ័រ សាវីយេ នៅស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ មានសិស្សចំនួន៨៨ភាគរយ បានប្រឡងជាប់សញ្ញាបត្រទុតិយភូមិក្នុងឆ្នាំ២០១៥នេះ។

កញ្ញាសួន សាវីយ៍ ជាអ្នកទទួលខុសត្រូវលើកម្មវិធីអប់រំ នៃព្រះសហគមន៍ស្វាយស៊ីសុផុនបានឲ្យដឹងថា ៖ នាឆ្នាំនេះ មណ្ឌលមានសិស្សចំនួន ៩នាក់ចូលរួម ប្រឡងសញ្ញាបត្រទុតិយភូមិ ជាលទ្ធផល មានសិស្សប្រឡងជាប់ ចំនួន ៨ នាក់ប៉ុន្តែធ្លាក់តែម្នាក់ទេ។

សិស្សដែលប្រឡងជាប់ទាំង ៨នាក់នេះ ទទួលបាននិទ្ទេស C ម្នាក់ និទ្ទេស D ២នាក់ និងនិទ្ទេសE ចំនួន៥នាក់ ។

កញ្ញាបានបន្តថា លទ្ធផលដែលទទួលបាននេះ គឺជាការផ្លាស់ប្តូរដ៏ល្អប្រសើរនៅក្នុងការសិក្សារបស់សិស្សក្នុងមណ្ឌលរបស់យើង ហើយក៏ជាក្តីសង្ឃឹមសម្រាប់ពួកគេក្នុងការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សាជាបន្តទៀតផងដែរ។

កញ្ញាសាវីយ៍ បានបន្ថែមថា "ដោយមើលឃើញនូវការយកចិត្តទុកដាក់រៀនសូត្រ និងមើលឃើញថា ចំណេះរបស់សិស្សនៅ មានកំរិតនៅឡើយ ទើបឆ្នាំនេះ មណ្ឌលយើងមានរៀបចំថ្នាក់រៀនប៉ប៉ិនសម្រាប់សិស្សក្នុងមណ្ឌល លើមុខវិជ្ជាមួយចំនួន ដោយជួលគ្រូពីខាងក្រៅឲ្យមកបង្រៀន"។

ការសិក្សាបន្ថែមទាំងនោះ គឺមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា អក្សរសាស្ត្រខ្មែរ និងភាសាអង់គ្លេស ។

មណ្ឌលណូប៊ីលី ជាកន្លែងស្នាក់នៅរបស់ព្រះសហគមន៍កាតូលិក សម្រាប់សិស្សដែលសិក្សានៅថ្នាក់វិទ្យាល័យ ។ ភាគច្រើនពួកគាត់មកពីស្រុក និងភូមិឆ្ងាយៗពីទីរួមខេត្ត និងជាសិស្សក្រីក្រ។ បច្ចុប្បន្ន មណ្ឌលនេះមានសិស្សសរុបចំនួន៣៦នាក់ដែលព្រះសហគមន៍ផ្ដល់អាហារូបករណ៍ ដោយទទួលឲ្យស្នាក់នៅ និងរៀនថ្នាក់វិទ្យាល័យនៅតាមសាលារដ្ឋ ។

*ដោយឡុង សម្ផស្ស*

# លោកបូជាចារ្យទទួលខុសត្រូវតាមមណ្ឌលសកម្មភាព
# ព្រះសហគមន៍នានាក្នុងភូមិភ្នំពេញ



**លោកបូជាចារ្យ ហ្វេរណាន់ដូ អារ៉ាំងហ្គោ**
ទទួលខុសត្រូវនៅព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវ។



**លោកបូជាចារ្យ វង្សម៉ាសែន ហាតាឆៃ**
(*លោកសាន់ដេ*) បូជាចារ្យជំនួយនៅព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវ។



**លោក បូជាចារ្យ យ៉ាំងលូកា តាខូឡា**
ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពកំពត។



**លោកបូជាចារ្យ ចន ពេញ**
បូជាចារ្យជំនួយនៅព្រះសហគមន៍មណ្ឌលសកម្មភាពកំពត-កែប។



**លោក បូជាចារ្យ អ៊ុន សុន**
ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពព្រះសីហនុ។



**លោកបូជាចារ្យ អាប្រាហាំ ខូន**
បូជាចារ្យជំនួយនៅព្រះសហគមន៍មណ្ឌលសកម្មភាពក្រុងព្រះសីហនុ។



# អ្នកស្វែងយល់ជំនឿរៀនអំពីព្រះសហគមន៍កាតូលិក



អ្នកស្វែងយល់ជំនឿ ប្រមាណជាង ៤០នាក់ នៅភូមិនៃព្រះសហគមន៍បុសខ្នុរ បានរៀនរួមគ្នា អំពីអ្វីជាព្រះសហគមន៍? កាលពីថ្ងៃទី ៩-១០ កញ្ញា ដែលស្ថិតនៅក្នុងភូមិ ១០មករា ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។

បុសខ្នុរ ជាព្រះសហគមន៍ថ្មីមួយ ដែលទើបនឹងកកើតឡើង ក្នុងឆ្នាំ ២០១៥ ហើយមកដល់ពេលនេះ មិនទាន់មានគ្រីស្តបរិស័ទកាតូលិក នៅឡើយទេ។

លោកបូជាចារ្យ ហ្វ្រង់ស័រ អេល្យដាល បានមានប្រសាសន៍ឲ្យដឹងថា៖ នៅទីនេះ ពុំមានគ្រីស្តបរិស័ទទេ គឺមានតែអ្នកកំពុងស្វែងយល់ អំពីជំនឿកាតូលិក មានដូចជា បងប្អូនខាងក្រុមប្រូតេស្តង់ និងពុទ្ធបរិស័ទ។

លោកបូជាចារ្យបន្តថា កម្មវិធីសិក្ខាសាលានេះ គឺដើម្បីឲ្យបងប្អូនទាំងនោះមានឱកាសក្នុងការជួបជុំគ្នា សិក្សាជាមួយគ្នា និងស្វែងយល់អំពីជំនឿ និងព្រះសហគមន៍កាតូលិក។ ជាពិសេសដើម្បីឲ្យពួកគេកាន់ តែមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះសហគមន៍ និងស្គាល់ ព្រះសហគមន៍កាតូលិកកាន់តែច្បាស់ថែមទៀត។

លោកបន្ថែមថា "នេះអាចនិយាយបានថា អ្នកទាំងនោះ គឺជាឫសគល់នៃជំនឿ សម្រាប់បន្តដល់អ្នកជំនាន់ក្រោយផងដែរ"។

លោកដួង សារ៉ង់ ជានាយកប្រតិបត្តិនៃមណ្ឌលអប់រំជំនឿ នៃព្រះសហគមន៍កាតូលិក និង ជាវាគ្មិនបានឲ្យដឹងថា សិក្ខាកាមទាំងអស់ បានយល់ដឹងអំពីប្រវត្តិព្រះសហគមន៍កាតូលិក តាំងពីដើមដំបូងបង្អស់ ដែលមានបព្វបុរសនៃជំនឿ និងការប្រកាសដំណឹងល្អតាមកន្លែងផ្សេងៗ រហូតមកដល់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា។ ជាមួយគ្នានេះក៏មាន ការពន្យល់អំពីភាពខុសគ្នានៃជំនឿរវៀងពុទ្ធសាសនា និងគ្រីស្តសាសនា និងការប្រតិបត្តិជំនឿខាងព្រះសហគមន៍កាតូលិក នៅក្នុងប្រទេសកម្ពុជា ដែលមានលក្ខណៈជាខ្មែរផងដែរ៕ *ដោយៈ ស្រីម៉ាច*

# យុវជនខ្មែរភាគតិចពាក់នាក់ប្រឡងជាប់ទុតិយភូមិ

នៅសម័យប្រឡងមធ្យមសិក្សា ទុតិយភូមិឆ្នាំ២០១៥នេះ សិស្សមកពីមណ្ឌលសិស្សសែនមនោរម្យ នៃខេត្តមណ្ឌលគិរីបីនាក់ បានប្រឡងជាប់ដោយជោគជ័យ។

"ខ្ញុំពិតជាសប្បាយចិត្តជាខ្លាំង នៅពេលឃើញលិទ្ធផលរបស់ខ្ញុំ បានជាប់យ៉ាងនេះ បើទោះបីជាខ្ញុំមិនបាននិទ្ទេសល្អដូចគេ តែខ្ញុំក៏បានជាប់ដូចសេចក្តីប្រាថ្នា"។ នេះជាសំដីរបស់កញ្ញា ច្រឹក ធីតា ជាយុវនារីមកពីមណ្ឌលសិស្សសែនមនោរម្យរបស់ព្រះសហគមន៍កាតូលិក។

មណ្ឌលសិស្សសែនមនោរម្យ ជាមណ្ឌលស្នាក់នៅរបស់សិស្សខ្មែរភាគតិចដែលព្រះសហគមន៍បានបង្កើតឡើងដើម្បីគាំទ្រការសិក្សារៀនសូត្ររបស់ខ្មែរភាគតិចក្រីក្រ។ មណ្ឌលនេះ មានទីតាំងស្ថិតក្នុងភូមិចំការតែ ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី។

ធីតាបន្តថា៖ វាមិនងាយស្រួលនោះទេក្នុងការសិក្សា លុះត្រាតែយើងមានក្តីស្រមៃច្បាស់លាស់ និងខិតខំប្រឹងប្រែងរៀនសូត្រជាប្រចាំ ស្រលាញ់ការសិក្សា ព្យាយាមស្រាវជ្រាវ និងធ្វើលំហាត់ឲ្យបានច្រើន ទើបលទ្ធផលនៃការសិក្សារបស់យើងល្អទៅតាមនោះដែរ។

ធីតាបន្ថែមថា "បងប្អូនជនជាតិព្នងមានអ្នកខ្លះមិនសូវចេះនិយាយភាសាខ្មែរនោះទេ។ ហេតុនេះអ្វីដែលសំខាន់នោះគឺយើងដែលជាយុវជនជំនាន់ក្រោយត្រូវព្យាយាមរៀន"។

ធីតាមានសុទិដ្ឋិនិយមថា គំរូរបស់ពួកគាត់ អាចនឹងបណ្តាលឲ្យយុវជនជំនាន់ក្រោយបើកចិត្តចំពោះការសិក្សា។ ធីតា បន្តថា នៅក្នុងភូមិស្រុករបស់នាងភាគច្រើនយុវជនឈប់រៀន អ្នកខ្លះរៀបការ និងអ្នកខ្លះទៀតធ្វើស្រែចំការតាមទំលាប់របស់ជនជាតិរបស់ខ្លួន។

លោកសាឡាសាណូ យ៉ូហាន យេស៊ូ (ហ៊ាន់)ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កាតូលិកខេត្តមណ្ឌលគិរី បានឲ្យដឹងថា៖ លោកពិតជាមានអំណរសប្បាយចំពោះលទ្ធផលរបស់យុវជនទាំងបីនាក់ដែលបានខិតខំប្រឹងប្រែងប្រឡង ទោះបីជាមានការរឹតបន្តឹងពិតមែន តែពួកគេនៅតែខិតខំធ្វើបានល្អ នេះជាមោទនភាពមួយសម្រាប់បងប្អូនជនជាតិ។

លោកបូជាចារ្យ រូបនេះបន្តថា៖ ពេលខ្លះ ការសិក្សារបស់ពួកគេជួបនូវឧបសគ្គ គឺអ្នកខ្លះចង់ឈប់រៀនដើម្បីរកលុយជួយគ្រួសារ និងអ្នកខ្លះទៀតចង់ឈប់ដោយសារតែមានបញ្ហាផ្សេងៗ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏លោកនៅតែជំរុញ និងលើកទឹកចិត្តពួកគេឲ្យបន្តការសិក្សា ដើម្បីឲ្យពួកគេអាចចេះថ្លឹងថ្លែង និងមើលឃើញអនាគតមួយដ៏ប្រសើរ ។ លោក ហ៊ាន់ "មានគោលបំណងមួយ គឺចង់ឲ្យបងប្អូនយុវជនយុវនារីជនជាតិព្នងមានចំណេះដឹងខ្ពស់ មានការងារល្អប្រសើរនៅក្នុងសង្គម"។

ដោយៈ *រឿន ស្រីម៉ាច*

# អធិដ្ឋានរាល់ថ្ងៃដើម្បីពង្រឹងជំនឿ

ជារៀងរាល់ថ្ងៃ គ្រីស្តបរិស័ទ និង យុវជនប្រមាណជា ៥០នាក់ នៅព្រះសហគមន៍កាតូលិកកោះរកា ស្ថិតនៅក្នុងខេត្តកំពង់ចាម តែងតែជួបជុំគ្នា ដើម្បីអធិដ្ឋានមជាមួយគ្នា ដើម្បីពង្រឹងជំនឿក៏ដូចជា ទំនាក់ទងល្អជាមួយព្រះសហគមន៍។

លោកបូជាចារ្យ ផាន បូរី ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសគមន៍កាតូលិកកោះរការ បានប្រាប់ឲ្យដឹងថា យុវជន និង គ្រីស្តបរិស័ទនៅកោះរការ តែងតែគិតថា ព្រះវិហារប្រៀបដូចជាផ្ទះទីពីររបស់ខ្លួន។ លោកបន្ថែមថា បើទោះបីជាមានភ្លៀងខ្លាំងយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែព្យាយាមអធិដ្ឋានជាមួយគ្នា ទាំងពេលសប្បាយចិត្ត និង ពេលពិបាកចិត្ត ព្រោះថាសកម្មភាពមួយនេះបានធ្វើឲ្យពួកគាត់ មានភាពរឹងមាំខាងផ្នែកជំនឿជាខ្លាំង។

លោកបូជាចារ្យ បូរីបន្តថា "ពេលខ្លះយើងរួមគ្នា ដើម្បីចែករំលែកព្រះបន្ទូលដំណឹងល្អ ចែករំលែកបទពិសោធន៍ខាងផ្នែកជំនឿ ដើម្បីឲ្យបងប្អូនទាំងនោះ មានអំណរសប្បាយជាមួយគ្នា និងបានធូស្បើយ ពីទុក្ខកង្វល់ទាំងឡាយដែលគេកំពុងជួប"។

ចំណែកកញ្ញា ហៃ សៀង លីន ជាគ្រីស្តបរិស័ទនៅកោះរការ បានប្រាប់ឲ្យដឹងថា៖ ក្រោយពេលចូលរួមកម្មវិធីអធិដ្ឋានជាមួយនឹងយុវជន ក៏ដូចជាគ្រីស្តបរិស័ទ ធ្វើឲ្យកញ្ញា មានអំណរសប្បាយជាខ្លាំង ដោយបានភ្លេចអស់នូវទុក្ខកង្វល់ទាំងឡាយ ដែលកំពុងតែកើតមានឡើងក្នុងជីវិត។

សៀងលីនបន្តថា "អ្វីដែលសំខាន់នោះគឺកម្មវិធីអធិដ្ឋាននេះ បានធ្វើឲ្យយើងម្នាក់ៗ កាន់តែមានភាបជិតស្និតជាមួយព្រះជាម្ចាស់ ដឹងសុខទុក្ខគ្នាទៅវិញទៅមក ស្រលាញ់ព្រះជាម្ចាស់ និងព្រះសហគមន៍ ក៏ដូចជាអ្នកនៅជុំវិញខ្លួន និងជាពិសេស បានព្យាបាលជំងឺផ្លូវចិត្តម្យ៉ាងដែរ"។

កញ្ញាបន្តថា ក្នុងមួយថ្ងៃយើងម្នាក់ៗធ្វើការងារជាច្រើន តែយើងមិនបាននឹកដល់ព្រះជាម្ចាស់នោះទេ ហេតុនេះយើងត្រូវតែរកពេលវេលាមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់អ្វីៗគ្រប់យ៉ាងដែលយើងបានទទួលនេះ។

កម្មវិធីអធិដ្ឋាននេះ គឺចាប់ផ្តើមនៅក្នុងអំឡុងពេល ម៉ោង៧ ដល់ម៉ោង ៧កន្លះជារៀងរាល់ថ្ងៃ៕

*ដោយរឿន ស្រីម៉ាច*

# ការលំបាកនិងឧបសគ្គជំរុញជំនឿឲ្យទៅមុខ



ព្រះសហគមន៍កាតូលិក កំពង់ចាមក្រុង បានរៀបចំដំណើរបូជនីយសក៍ដោយជិះកង់ ពីព្រះសហគមកន៍កាតូលិកកំពង់ចាមក្រុងទៅព្រះសហគមន៍កាតូលិកបុសខ្នុរ គឺជាព្រះសហគមន៍ដែលទើបតែកកើត ក្នុងភូមិភាគកំពង់ចាមកាលពីថ្ងៃទី១៨ កញ្ញា។

លោក ហ្វ្រង់ស័រ អេមេល្យដាល ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កំពង់ចាមក្រុងបានប្រាប់ឲ្យដឹងថា នេះគឺជាកម្មវិធីមួយធ្វើឡើងក្នុងមួយឆ្នាំម្តង ជាមួយយុវជនយុវនារី ឬជាមួយនិងគ្រីស្តបរិស័ទផងក៏មាន។ លោកបន្តថា "អ្វីដែលសំខាន់នោះ គឺព្រះសហគមន៍ចង់ឲ្យយើងម្នាក់ៗចេះតស៊ូនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ថាយើងត្រូវឆ្លងកាត់អ្វីខ្លះ? ព្យាយាមយ៉ាងដូចម្តេចខ្លះ? និងបន្តទៅមុខ ដោយរបៀបណាខ្លះក្នុងដំណើរជីវិត"។

ដំណើរការជិះកង់នេះ បានធ្វើឡើងតាំងពីព្រលឹម ចេញពីព្រះសហគមន៍កំពង់ចាមក្រុង ទៅព្រះសហគមន៍កាតូលិកបុសខ្នុរ ដែលមានចំងាយប្រមាណជាង២០គីឡូម៉ែត ដោយមានយុវជនជាគ្រីស្តបរិស័ទ ដែលមកពីព្រះសហគមន៍ផ្សេងៗ និងក្រុមបុគ្គលិកនៃព្រះវិហារកំពង់ចាមជាង ៣០ នាក់។

យុវជន ម៉េង យូ មកពីព្រះសហគមន៍កាតូលិកកោះរការ បានប្រាប់ឲ្យដឹងថា "ខ្ញុំហត់មែនតែវាបានធ្វើឲ្យខ្ញុំចេះតស៊ូក្នុងការបន្តរដំណើរទៅមុខ រួមជាមួយអ្នកផ្សេងទៀត។ ហើយវាប្រៀបដូចជាខ្ញុំ កំពុងតែខិតខំព្យាយាមយ៉ាងខ្លាំង ដើម្បីទៅជួបព្រះវិហារថ្មីនេះ ឬអាចនិយាយបានទៀតថា នៅពេលដែលយើងពិបាក គឺធ្វើឲ្យយើងចេះតស៊ូនៅក្នុងជីវិត។ ហើយនៅទីបំផុត យើងទាំងអស់គ្នាទទួលបានជោគជ័យដោយសារតែការខិតខំរបស់យើងម្នាក់ៗ"។

រីឯអ្នកស្រី នួន ស៊ីណាត ជាគ្រីស្តបរិស័ទ នៅព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង បានឲ្យដឹងថា អ្នកស្រីមានអារម្មណ៍ថា សប្បាយចិត្តជាខ្លាំង នៅពេលបានធ្វើដំណើរ ដោយជិះកង់ ពីព្រោះវាជាកម្មភាពមួយ ដែលពង្រឹងជំនឿរបស់យើងម្នាក់ៗ ឲ្យខិតខំតស៊ូនៅក្នុងការធ្វើដំណើរ ដើម្បីទៅជួបព្រះជាម្ចាស់ បើទោះបីជាវាពិបាកយ៉ាងណាមានបញ្ហាយ៉ាងណាក៏ដោយ។ អ្នកស្រីបន្ថែមថា "ហេតុនេះ ធ្វើឲ្យខ្ញុំក៏ដូចជាអ្នកដែលបានចូលរួមទាំងអស់ បានដឹងពីកម្លាំងរបស់ខ្លួន និងការពីជំនឿរបស់ខ្លួន"។ អ្នកស្រីបន្តថា វាហាក់ដូចជាហត់នឿនិងអស់កម្លាំងបន្តិច ព្រោះថាយើងធ្វើដំណើរ ក្រោមពន្លឺថ្ងៃក្តៅខ្លាំង ហើយតាមផ្លូវវែងឆ្ងាយ ពេលខ្លះយើងពិតជាចង់ឈប់ និងមិនចង់បន្តដំណើរទៅមុខទៀតទេ តែពេលដែលឃើញបងប្អូនផ្សេងទៀត អាចទៅមុខបានដោយរីករាយអ្នកស្រីក៏ព្យាយាមទៅមុខ ដោយសេចក្តីសង្ឃឹម។ អ្នកស្រី ណាតបន្តថា៖ "នៅពេលដែលយើងបានទៅដល់គោលដៅ ហើយទើបយើងដឹងថាអ្វីដែលយើងបានខិតខំគឺពិតជាមានតម្លៃ"។

*ដោយស្រីម៉ាច*

# កុមារនៅកំពង់ចម្លងមានអាគារសិក្សាថ្មី

អាគារសាលាបឋមសិក្សា ព្រះហឫទ័យ ប្រណីសន្ដោសព្រះយេស៊ូ ចំនួនមួយខ្នង ដែលមានទំហំ ១៥៣ ម៉ែត្រការ៉េ ត្រូវបានសម្ពោធជាផ្លូវការ ដោយលោកអភិបាល អូលីវីយេ ជ្មឹតអឺស្លែរ នាថ្ងៃទី៨ សីហា ២០១៥ ដោយមានអ្នកចូលរួមជាង ២០០នាក់ នៅព្រះសហគមន៍សន្ត ម៉ាតាំង កំពង់ចម្លង ភូមិព្រែកទម្លាប់ ស្រុកលើកដែក ខេត្តកណ្ដាល។

បងប្រុស កែវ សុវណ្ណ នៃក្រុមគ្រួសារបេសកកម្មនៃព្រះមាតា បានឲ្យដឹងថា សាលារៀននេះ បានកសាងឡើងក្នុងឆ្នាំ ១៩៩៣ ដើម្បីឲ្យកុមារ ដែលគ្មានឱកាសទទួលការសិក្សា បានទទួលការអប់រំ និងចំណេះដឹងដូចក្មេងៗដទៃទៀត។ បងប្រុសបានបន្តថា ដោយសារអាគារចាស់ទ្រុឌទ្រោម និងមិនអាចរៀនបន្តបាន ហេតុដូចនេះ ព្រះសហគមន៍ បានផ្ដើមកសាងសាលានេះឡើងវិញកាលពីថ្ងៃទី ១៧ កក្កដា ២០១៤ និងបញ្ចប់ កាលពីចុងឆ្នាំ ២០១៤ កន្លងទៅ ដោយចំណាយថវិការអស់ ៣១៩១០ ដុល្លារអាមេរិក ក្រោមការឧបត្ថម ពីព្រះសហគមន៍ និងសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេស។



*លោកអភិបាលអូលីវីយេ កាត់ខ្សែរបូសម្ពោធអគារសិក្សាថ្មីនៅកំពង់ចម្លង។ រូបភាពៈ ឡុង សម្ផស្ស*

លោកអភិបាល អូលីវីយេ បានប្រទានពរដល់អាគារថ្មី និងសូមព្រះជាម្ចាស់ប្រទានពរ ដល់អស់អ្នកដែលបានកសាងសាលានេះ ទាំងអ្នកជួយទាំងមាតាបិតា និងលោកគ្រូអ្នកគ្រូទាំងអស់ដែលខិតខំតស៊ូ ដើម្បីឲ្យក្មេងៗមានជីវិតល្អនៅក្នុងសង្គម។ លោកអភិបាលបន្ថែមថា លោកជឿជាក់ថាសាលានៅទីនេះ គឺជាឱកាសមួយឲ្យកុមារស្គាល់ និងដើរតាមគំរូរបស់ព្រះយេស៊ូ និង ដើម្បីស្វែងយល់ពីសេចក្ដីពិត ។ លោកអភិបាលបញ្ជាក់ថា យើងត្រូវការចំណេះដឹង ហើយសាលានេះជាកន្លែងរៀនអក្ខរកម្ម និងជាកន្លែងរិះគិតដើម្បីរៀបចំជីវិត នាពេលបច្ចុប្បន្ន និងនាពេលអនាគត។

លើសពីនេះ លោកអូលីវីយេ បានក្រើនរំឭកដល់មាតាបិតា និងអាណាព្យាបាល ជួយជំរុញឲ្យក្មេងៗ បានចូលរៀន និងរៀបចំអនាគត ដើម្បីដើរតាមព្រះគ្រីស្ដ។ លោកបន្តផ្ដាំផ្ញើរដល់ក្មេងៗទាំងអស់ឲ្យ ត្រូវខិតខំរៀនសូត្រដើម្បីមានចំណេះដឹងផ្ទាល់ខ្លួនផងដែរ។បងប្រុស កែវ សុវណ្ណបានឲ្យដឹងទៀតថា ជាង២០ឆ្នាំនេះ ព្រះសហគមន៍បានបណ្ដុះបណ្ដាលកុមារ អំពីអក្ខរកម្មជាភាសាខ្មែរ ហើយនៅឆ្នាំ ២០១៤ កន្លងទៅ ព្រះសហគមន៍បានទទួលការអនុញ្ញាត ឲ្យបង្កើត ជាសាលាបឋមសិក្សាឡើង។ បច្ចុប្បន្នសាលាបឋមសិក្សានេះមានចំនួន២ថ្នាក់ គឺថ្នាក់ទី១ និងទី២ រៀនព្រឹកល្ងាច មានសិស្សចំនួនប្រមាណ៧០នាក់។ ក្រោយពីបញ្ចប់ការសិក្សានៅសាលានេះ កុមារទាំងនោះនឹងត្រូវបញ្ជូនទៅរៀននៅសាលារដ្ឋ នៅថ្នាក់ទី៣បន្តទៀត៕

*ដោយដាលីស*

# បោះជំរំដើម្បីជំរុញកុមារឲ្យយល់ពីធម្មជាតិ



ធម្មជាតិ ជាផ្ទះរបស់យើង ជាប្រធានបទសម្រាប់កម្មវិធី បោះជំរំកុមារ របស់ព្រះសហគមន៍ កាតូលិក មណ្ឌលសម្មភាពភ្នំពេញខាងជើង ធ្វើឡើងដើម្បីឲ្យកុមារទាំងអស់ បានយល់ដឹងបន្ថែមអំពីអត្ថប្រយោជន៍ របស់ធម្មជាតិ និងរបៀប នៃការថែរក្សាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

លោកប្រុយណូ កូសម៍ ជាបូជាចារ្យទទួលខុសត្រូវ មណ្ឌលសកម្មភាពភ្នំពេញខាងជើង បានមានប្រសាសន៍ឲ្យដឹងថា កម្មវិធីបោះជំរំនេះ គឺធ្វើឡើងដើម្បីដាស់ស្មារតីរបស់កុមារ ឲ្យចេះចូលរួមថែរក្សានូវធម្មជាតិ ដែលប្រៀបដូចជាផ្ទះរបស់ពួកគេ។ លោកក៏បានលើកឡើងទៀតថា ការរិះគិតអំពីធម្មជាតិនេះ គឺឲ្យស្របទៅនឹងការអំពាវនាវ របស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលបានផ្ញើសារលិខិតមួយ របស់ព្រះអង្គជូនគ្រីស្តបរិស័ទទូទាំងពិភពលោក ស្ដីអំពីបរិស្ថានធម្មជាតិ និង ការទំនាក់ទំនងរបស់មនុស្ស និងបរិស្ថាន ដែលនៅជុំវិញខ្លួនរបស់យើង ។

លោកបូជាចារ្យបញ្ជាក់ថា "ព្រះជាម្ចាស់ ជាអ្នកបង្កើតអ្វីៗទាំងអស់ ហើយធម្មជាតិ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ធម្មជាតិ និងពិភពលោក គឺជាផ្ទះរបស់យើង មិនមែនជាផ្ទះ ដែលធ្វើពីឈើពីថ្មនោះទេ ធម្មជាតិគឺពាក់ព័ន្ធទៅនឹងសង្គមរបស់យើង។ ហើយធម្មជាតិ ជាផែនដីទាំងមូលនេះ និងអ្វីៗទាំងអស់ ដែលនៅជុំវិញខ្លួនរបស់យើង ជាធម្មជាតិទាំងអស់"។

កម្មវិធីបោះជំរំកុមារនេះបានធ្វើឡើងនៅព្រះសហគមន៍ផ្សារតូច នារាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ រហូតដល់ ៣១ ខែសីហា ដែលមានកុមារចូលរួមប្រមាណជិត ១០០នាក់ មកពីព្រះសហគមន៍ចំនួន៥ គឺផ្សារតូច គីឡូម៉ែត្រលេខ១១ សែនសុខ ព្រែកតាទែន និងអរិយក្សត្រ។

*ដោយឡុង សម្ផស្ស*

# យុវជន និងកុមារស្វែងយល់ពី ការបម្រើដោយក្តីស្រលាញ់




ព្រះសហគមន៍ ព្រះយេស៊ូសង្គ្រោះមនុស្សលោក (អំពៅព្រៃ) បានរៀបចំបោះជំរំកុមារនិងយុវជនដែលមានចំនួន ៨៩នាក់ កាលពីថ្ងៃទី១៩ ដល់២៦ កញ្ញា ស្ថិតនៅ ក្នុងភូមិតាដោល ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

កុមារ និង យុវជនទាំងនោះមកពីតាមភូមិមួយចំនួន នៅក្នុងស្រុកកណ្តាលស្ទឹង ដូចជា៖ អំពៅព្រៃ ទឹកនឹម តាដោល ដើងព្រៃ ស្វាយព្រៃ តោតម៉ា បឹង៩៤។ កម្មវិធីបោះជំរំនេះ បានប្រព្រឹត្តទៅចំនួន២វគ្គ គឺសម្រាប់យុវជន ៥៨នាក់ កាលថ្ងៃទី ១៩-២២ ខែកញ្ញា និងសម្រាប់កុមារនៅថ្ងៃទី ២៣-២៦ ខែកញ្ញា ដែលមានកុមារចូលរួម ៨៩នាក់។

លោកម៉ារីយ៉ូ ហ្កេហ្ស៊ី បូជាចារ្យទទួលខុសត្រូវ នៅមណ្ឌលសកម្មភាពតាខ្មៅ មានប្រសាសន៍ថា ការបោះជំរំនេះ គឺដើម្បីបង្កើនទំនាក់ទំនងរវាងកុមារ និងកុមារ និងយុវជននិងយុវជន ព្រមទាំងលើកទឹកចិត្តបណ្តុះគំនិតយុវជន ពីរបៀបរស់នៅក្នុងគ្រួសារ និង ក្នុងសង្គម។ ម្យ៉ាងវិញទៀត ព្រះសហគមន៍ចង់ បង្ហាត់បង្ហាញមុខវិជ្ជាផ្សេងៗ និងបង្កើនបរិយាកាសសប្បាយៗរីករាយនៅជាមួយគ្នា ក្នុងឱកាសវិស្សមកាលរបស់យុវជន និងកុមារ។

យុវជន រិទ្ធ រាជ មានអាយុ ២០ឆ្នាំ ដែលរស់នៅក្នុងព្រះសហគមន៍ អំពៅព្រៃបានឲ្យដឹងថា៖ ការបោះជំរំនេះធ្វើឲ្យប្អូនស្គាល់គ្នា ទទួលភាពជិតស្និទ្ធ សាមគ្គីភាព ទំនាក់ទំនងល្អ ការផ្តល់ក្តីស្រឡាញ់រវាងគ្នានិងគ្នា។ រាជ បានប្រាប់ទៀតថា គាត់មានអារម្មណ៍រំភើបពេលបាន ចុះសួរសុខទុក្ខចាស់ជរា គ្រួសារក្រីក្រ និងចែកទានដល់ពួកគាត់ ដូចជាគ្រឿងឧបភោគបរិភោគ ព្រមទាំងជួយសម្អាតភូមិ ដែលនៅជុំវិញព្រះសហគមន៍អំពៅព្រៃ។

យុវជន ជា សុភា មានអាយុ ១៧ឆ្នាំ និយាយថា ការចូលរួមការបោះជំរំនេះធ្វើសុភាយល់ច្បាស់ពី សុជីវធម៌ សីលធម៌ និងគុណធម៌ ដើម្បីរស់នៅក្នុងសង្គមជាមួយនឹងភាពថ្លៃថ្នូរ។ សុភាបន្តថា គាត់មានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំងដោយបានឃើញ ពីការបម្រើរវាងកុមារ និងកុមារ យុវជន និងយុវជន ជាពិសេសការបម្រើដល់ចាស់ជរា និងគ្រួសារក្រីក្រដោយក្តីស្រលាញ់។

យុវនារី ផង់ ស្រីនាង អាយុ១៥ឆ្នាំ ដែលរស់នៅក្នុងមណ្ឌលផ្ទះនៃក្តីសង្ឃឹម នៃព្រះសហគមន៍អំពៅព្រៃ និយាយថា "ខ្ញុំស្រឡាញ់ និងពេញចិត្តក្នុងការចូលរួមបោះជំរំ ទោះបីជាអស់កម្លាំង ក្តៅភ្លៀងធ្លាក់ តែសប្បាយដោយឃើញភាពរីករាយរបស់ក្រុមផ្ទាល់ និងក្រុមដែលបានចូលរួម"។ ស្រីនាង បន្តថា ព្រះសហគមន៍ ជាន្លែងដែលមនុស្សគ្រប់ជាតិសាសន៍ អាចស្គាល់គ្នាមិនរើសអើងគ្នា និងស្រលាញ់គ្នាដូចជាបងប្អូនបង្កើត៕

# ព្រះសហគមន៍ជំរុញឲ្យគ្រីស្តបរិស័ទធ្វើកិច្ចសង្គហៈ

ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ បានរៀបចំវេទិកាស្តីអំពីមេត្តាករុណា និង ប្រកាសបើកឆ្នាំមហាករុណាទិគុណសម្តែងព្រះហឫទ័យ ប្រណីសន្តោស ដោយមានអ្នកចូលរួមពីគណៈកម្មការសង្គហៈ តំណាងក្រុមយុវជន តំណាងក្រុមកាយឫទ្ធិ និង តំណាងអង្គការនានានៃសម្ពន្ធកាតូលិកដើម្បីមេត្តាករុណា និងការអភិវឌ្ឍន៍ (CACD) សរុបប្រមាណជិត ៣០០នាក់ ដើម្បីលើកទឹកចិត្តរិះគិតបន្ថែម និង ជំរុញឲ្យមានសកម្មភាព មេត្តាករុណាបន្ថែមទៀតនៅក្នុងសង្គមកម្ពុជា។

កម្មវិធីនេះ ធ្វើឡើង នៅមណ្ឌលសកម្មភាពភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ក្រោមការដឹកនាំ របស់លោកអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ នាថ្ងៃទី២៣ ដល់២៥ កញ្ញា ២០១៥នេះ។

លោកអភិបាលអូលីវីយេ ឆ្មឺតអឺស្លែរ បានរំឭកសិក្ខាកាមទាំងអស់ អំពីបេសកកម្មរបស់យើង ជាគ្រីស្តបរិស័ទឲ្យចូលរួមក្នុងបេសកកម្ម ជាសង្គហៈ ដោយបញ្ជាក់ថា តួនាទីនៃមេត្តាករុណាមិនមែនត្រឹមតែ ក្រុមសង្គហៈប៉ុណ្ណោះ ទេតែជាតួនាទី របស់យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ។

លោកអភិបាល បានបន្តអប់រំ ឲ្យគ្រីស្តបរិស័ត ចេះយកគំរូតាមក្រុមគ្រីស្តទូត ដោយស្តាប់ព្រះបន្ទូលបង្រៀន ឬ អានព្រះគម្ពីរ អធិដ្ឋាន និងចែករំលែកទ្រព្យសម្បត្តិដែលខ្លួនមាន ដល់អ្នកតូចតាច ដើម្បីឲ្យពួកគេ បានរស់នៅសមរម្យ។ លោកបន្ថែមថា "សម្មភាពទាំងនេះជំរុញឲ្យយើងមានក្រុមសំខាន់ទាំងបីគឺ ក្រុមអប់រំជំនឿ ក្រុមពិធីបុណ្យ និងក្រុមសង្គហៈ"។

ជាមួយគ្នានេះដែរ ក៏មានបទបង្ហាញរបស់សម្ពន្ធកាតូលិកដើម្បីមេត្តាករុណា និងការអភិវឌ្ឍន៍ អំពីសកម្មភាពនានា ដែលមានដូចជា ការអប់រំ កម្មវិធីសុខភាព កម្មវិធីអភិវឌ្ឍន៍សហគមន៍ កម្មវិធីជនពិការ កម្មវិធីកម្មករ និង ជនចំណាកស្រុក និងកម្មវិធីគ្រោះមហន្តរាយធម្មជាតិ។

លោកគីម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា និយាយថា "ឆ្នាំមេត្តាករុណា ជាឆ្នាំមួយយ៉ាងពិសេស ដែលជំរុញឲ្យអង្គការការីតាស កាន់តែយកចិត្តទុកដាក់បន្ថែម អំពីទស្សនវិស័យរបស់ខ្លួន ជាពិសេសការសម្តែងមេត្តាករុណាដល់អស់អ្នកដែលខ្វះខាត ដល់អស់អ្នក ដែលត្រូវគេបោះបង់ចោល ដល់អស់អ្នក ដែលសង្គមមិនសូវយកចិត្តទុកដាក់។ ដូច្នេះយើង ឃើញសកម្មភាពរបស់អង្គការ មានសឹងគ្រប់វិស័យ ស្របតាមការណែនាំរបស់ព្រះសហគមន៍កាតូលិក"។

នៅក្នុងកម្មវិធីនោះដែរ ក៏មានការបញ្ចាំងពីរឿងអ្នកម្តាយតេរេសា ដើម្បីបង្ហាញឲ្យអ្នកចូលរួមទាំងអស់យល់អំពីសកម្មភាពនៃមេត្តាករុណាដោយគួបផ្សំជាមួយជំនឿលើព្រះយេស៊ូ។

លោក នូ ចាន់សារឿន ជាក្រុមសង្គហៈមកពីក្រុងព្រះសីហនុ បានឲ្យដឹងថា សិក្ខាសាលាបានផ្តល់ឲ្យយើងទាំងអស់គ្នាជាគណៈកម្មការសង្គហៈឲ្យស្គាល់ពីតម្លៃ និងការទទួលខុសត្រូវរបស់គណៈកម្មការយើង ដែលជាអ្នកនាំដំណឹងល្អដល់ជនក្រីក្រ ព្រោះពីមុនគណៈកម្មការរបស់យើងតែងតែសម្រេចចិត្តដោយខ្លួនឯង និងគ្មានច្បាប់ទំលាប់អ្វីឡើយ។ លោកសារឿនអះអាងថា នឹងផ្សព្វផ្សាយដល់អស់បងប្អូនផ្សេងៗ ឲ្យបានដឹងពីតួនាទីជាគ្រីស្តបរិស័ទ និងខិតខំឲ្យពួកគាត់ ចូលរួមជាមួយគណៈកម្មការសង្គហៈដែរ។

អ្នកស្រី ឡែមករា នាយិការង នៃវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ បាននិយាយថា "ការជួយអ្នកក្រីក្រ គឺមិនថាទាំងកម្លាំងទាំងស្មារតី ក៏ដូចជាការលើកទឹកចិត្ត ជាពិសេស គឺបង្ហាញនូវសេចក្តីស្រឡាញ់ដែលយើងមាន។ ការជួយគាត់ផ្តល់សេចក្តីសង្ឃឹម មិនថាទាំងសម្ភារ ជំនឿដែលយើងមាន ជូនដល់ពួកគាត់"។

លោកលី សុជា អ្នកសម្របសម្រួលបឋមសិក្សា និងអក្ខរកម្មព្រះសហគមន៍កាតូលិកឲ្យដឹងថា "ចំពោះមេត្តាករុណានេះ គឺត្រូវចេញពីចិត្តរបស់យើងជាមុនសិន ទើបយើងអាចធ្វើមេត្តាករុណាទៅដល់អ្នកដទៃបាន។ បើមនុស្សគ្មានធម៌មេត្តាករុណាទេ សង្គ្រាមវាកើតឡើង"។

លោក នូ ម៉ុនសារិទ្ធ ប្រធានផ្នែកសិទ្ធិមូលដ្ឋាន និងតស៊ូមតិរបស់អង្គការការីតាសកម្ពុជា បានឲ្យដឹងថា "ការបង្ហាញធម៌មេត្តាករុណា របស់ព្រះជាម្ចាស់ ដើម្បីឲ្យយើងចេះស្រឡាញ់បងប្អូន និងអ្នកក្រីក្រ ឲ្យយើងចេះអាណិតអាសូរដល់ពួកគាត់ ជំរុញឲ្យពួកគាត់ចាកផុតពីភាពក្រីក្រទាំងឡាយ។

ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញបានរៀបចំឆ្នាំ នៃមេត្តាករុណានេះ ចំនួន២ឆ្នាំមកហើយ គឺពីឆ្នាំ ២០១៤មក។

លោកយ៉ាន ជីហ្មុង ជាគណៈកម្មាការពលករឲ្យដឹងថា "មេត្តាករុណា មិនមែនត្រឹមតែជួយអ្នកដទៃទេ ជាការទទួលសេចក្តី ស្រឡាញ់មកពីព្រះជាម្ចាស់ ហើយឲ្យមនុស្សឯទៀតៗវិញ។ សំខាន់គឺជួយគេ ឲ្យគេជួយខ្លួនឯង។ មេត្តាករុណា ដែលល្អជាងគេបំផុតគឺ យុត្តិធម៌។ ពេលមានយុត្តិធម៌ មិនត្រូវការមេត្តាករុណាច្រើន ដូចសង្គមអយុត្តិធម៌ទេ"។

លោក ស៊ុន ណម មកពីព្រះសហគមន៍កោះស្លា "ឆ្នាំមេត្តាករុណាទិគុណរបស់ព្រះជាម្ចាស់ ផ្តល់កម្លាំងថ្មីមួយសម្រាប់ខ្ញុំ ដើម្បីឲ្យខ្ញុំមានសកម្មភាពរស់រវើកកាន់តែខ្លាំង ជួយអ្នកមានវិបត្តិនៅក្នុងសហគមន៍"។

ក្នុងកម្មវិធីនោះដែរ លោកអភិបាលបានរំឭកដល់គ្រីស្តបរិស័ទទាំងអស់ ឲ្យយល់ថា តួនាទីចម្បងរបស់យើងគឺប្រកាសដំណឹងល្អអំពីព្រះយេស៊ូ ដែលយាងមក ដើម្បីឲ្យមនុស្សលោករកឃើញជីវិតថ្មីហើយគ្រប់សក្ខីភាព និងសកម្មភាពដែលយើងធ្វើរាល់ថ្ងៃ គឺបង្ហាញ និងប្រកាសដំណឹងល្អអំពីព្រះយេស៊ូ។ លោកអូលីវីយេទទូចឲ្យគ្រីស្តបរិស័ទទាំងនោះ បន្តថែរក្សាភាតរភាពរវាងគ្នា និងគ្នារក្សាការសន្ទនារក្សាជំនឿក្នុងការរស់នៅយ៉ាងពិតប្រាកដ និងយកចិត្តទុកដាក់ ព្រមទាំងតស៊ូដើម្បីប្រកាសដំណឹងល្អ ដោយសម្តែងមេត្តាករុណាជាពិសេស ចំពោះអ្នកដែលសង្គមមិនរវីរវល់។

ក្នុងកម្មវិធីនោះដែរ លោកអភិបាលបានរំឭកដល់គ្រីស្តបរិស័ទទាំងអស់ ឲ្យយល់ថា តួនាទីចម្បងរបស់យើងគឺប្រកាសដំណឹងល្អអំពីព្រះយេស៊ូ ដែលយាងមក ដើម្បីឲ្យមនុស្សលោករកឃើញជីវិតថ្មីហើយគ្រប់សក្ខីភាព និងសកម្មភាពដែលយើងធ្វើរាល់ថ្ងៃ គឺបង្ហាញ និងប្រកាសដំណឹងល្អអំពីព្រះយេស៊ូ។ លោកអូលីវីយេទទូចឲ្យគ្រីស្តបរិស័ទទាំងនោះ បន្តថែរក្សាភាតរភាពរវាងគ្នា និងគ្នារក្សាការសន្ទនារក្សាជំនឿក្នុងការរស់នៅយ៉ាងពិតប្រាកដ និងយកចិត្តទុកដាក់ ព្រមទាំងតស៊ូដើម្បីប្រកាសដំណឹងល្អ ដោយសម្តែងមេត្តាករុណាជាពិសេសចំពោះអ្នក ដែលសង្គមមិនរវីរវល់។

នៅថ្ងៃចុងក្រោយ នៃវេទិកានេះ គណៈកម្មការនីមួយៗ ត្រូវបានពិភាក្សាគ្នា តាមមណ្ឌលសកម្មភាពរៀងៗខ្លួន ដើម្បីបង្កើតទិសដៅថ្មី ឲ្យស្របតាមលក្ខន្តិក នៃគណៈកម្មការង្គហៈសម្រាប់ឆ្នាំ២០១៥-២០១៦នេះ។ លក្ខន្តិកទាំងនោះរួមមាន៖ បេសកកម្មក្រុម សមាជិកភាពក្រុម កិច្ចការប្រជុំក្រុម ការចូលរួមក្នុងការអប់រំបណ្តុះបណ្តាល និង ការប្រើប្រាស់ ថវិកាដែលបានមកពីសប្បុរសជន និងពីព្រះសហគមន៍៕

*ដោយ ស្រីម៉ាច និងដាលីស*

# សម្ដេចប៉ាប ស្នើឲ្យគ្រប់ព្រះវិហារនៅទូទាំងអឺរ៉ុបបើកទ្វារទទួលជនភៀសខ្លួន

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពី ពេលថ្មីៗនេះ បានស្នើឲ្យបណ្ដាព្រះ វិហារ និងសហគមន៍សាសនានានានូវ ទូទាំងអឺរ៉ុប បើកទ្វារទទួលជនភៀស ខ្លួននានា ។

តាមការផ្សាយ របស់វិទ្យុវាទីកង់ បានឲ្យដឹងថា សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានស្នើសុំដូច្នេះ កាលពីថ្ងៃអាទិត្យ នៅ ក្នុងធម្មទេសនារបស់លោក ដែលបានធ្វើឡើងទៅគ្រិស្តបរិស័ទ នានានៅលើ ពិភពលោក កាលពីថ្ងៃអាទិត្យ ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ សូមឲ្យ បណ្ដាព្រះសហគមន៍ និង គ្រប់សហគមន៍សាសនា ទាំងអស់នៅទូទាំង ទ្វីបអឺរ៉ុប ទទួលយ៉ាងហោចណាស់ជនភៀសខ្លួនមួយគ្រួសារ ដើម្បីចែករំលែក ការលំបាករបស់ពួកគេ ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ជំនឿកំពុងតែស្នើរសុំ ឲ្យយើងទាំងអស់គ្នា មានសកម្មភាពពិតប្រាកដ ដើម្បី ផ្សព្វផ្សាយដំណឹងល្អ តាមព្រះគម្ពីរ ដើម្បីផ្ដល់នូវក្ដីសង្ឃឹម ដល់អ្នកដែលមានទុក្ខលំបាក៕

# គ្រីស្តបរិស័ទសែនសុខដឹកនាំកសាងផ្លូវក្នុងភូមិ

គ្រីស្តបរិស័ទ នៃព្រះសហគមន៍ សន្តយ៉ូសែបសែនសុខ (អន្លង់ក្ងាន) បានដឹកនាំប្រជាជនក្នុងភូមិ ដើម្បីកសាងផ្លូវក្នុងសហគមន៍ទី ១ ភូមិសែនសុខ ដែលជាភូមិដាច់ស្រយាលក្រៅក្រុងភ្នំពេញ។

លោក រឿង ផ័ត្រសិរី ជាបូជាចារ្យកាតូលិក ទទួលខុសត្រូវនៅព្រះសហ-គមន៍ សែនសុខ បានទទួលថវិកាពីសប្បុរសជន បានចំនួនតិចតួច ក៏ប្រគល់ឲ្យអ្នកស្រី ចាន់ធី ដែលជាគណៈកម្មការ ដឹកនាំព្រះសហគមន៍ នៅទីនោះ ដើម្បីធ្វើផ្លូវសម្រាប់ប្រជាជន។ លោកបូជាចារ្យ ផ័ត្រសិរី បានមានប្រសាសន៍ថា ក្រោយបានសហការជាមួយអ្នកភូមិ ទាំងខាងថវិកា ទាំងខាងពលកម្ម និងការលើកទឹកចិត្តក៏ធ្វើឲ្យភូមិមួយនេះ មានផ្លូវបេតុងមួយខ្សែប្រវែង ១១៦ ម៉ែត្រ ដែលបានចំណាយអស់ថវិការ ៧៧៩ ដុល្លារអាមេរិក។ កិច្ចការនេះក៏បានជូនដំណឹង និង មានរបាយការណ៍ ដល់សាលាខណ្ឌសែនសុខ ដើម្បីស្គាល់សកម្មភាពរបស់ព្រះសហគមន៍នៅតំបន់នោះផងដែរ។

នៅឆ្នាំ ២០០១ អ្នកភូមិ និងគ្រីស្តបរិស័ទ ដែលផ្ទះធេះនៅភូមិប៊ូឌីងក្នុងទីក្រុងភ្នំពេញ ត្រូវបានបណ្ដេញចេញឲ្យមករស់នៅតំបន់អន្លង់ក្ងាន ដោយគ្មាន ហេដ្ឋារចនាសម្ពន្ធគ្រប់គ្រាន់នៅឡើយ សូម្បីតែទឹក និងភ្លើងក៏គ្មាន។ ក្នុងរយៈពេលដប់ឆ្នាំក្រោយមក រដ្ឋាភិ-បាល បានរៀបចំបណ្ដាញទឹកភ្លើងដែលចាំបាច់ឲ្យប្រជាជន តែអត់មានថវិកាសម្រាប់ធ្វើផ្លូវក្នុងភូមិ នាំឲ្យអ្នកភូមិធ្វើដំណើរយ៉ាងពិបាកនៅរដូវភ្លៀង។

លោកបូជាចារ្យ ផ័ត្រសិរី បន្ថែមទៀតថា ដូចជាព្រះយេស៊ូបានចែកនំប៉័ង ៥ ដុំ និងត្រី ២ កន្ទុយឲ្យប្រជាជនកាលពីដើម ហើយកិច្ចការដែលមានថវិកាតិចតួចនេះ ក៏ធ្វើឲ្យប្រជាជនដែលគិតថាខ្លួនឯងជាអ្នកក្រីក្រ ក៏អាចចែករំលែកគ្នា ទៅវិញទៅមកបាន ហើយនាំឲ្យព្រះសហគមន៍ក្លាយទៅជាទីសម្គាល់សម្រាប់មហាជនទូទៅ អំពីធម៌មេត្តារបស់ព្រះយេស៊ូ។



*អ្នកភូមអន្លង់ក្ងានសហកាណ៍គ្នាចាក់ផ្លូវបេតុង។ រូបថតៈ សហការី*

ដោយសារសកម្មភាពនេះដែរ បានជំរុញឲ្យប្រធានសហគមន៍ សុំថវិកាពីរដ្ឋ ដើម្បីបន្ថែមផ្លូវដែលមិនទាន់ធ្វើចំនួន៣ ខ្សែទៀតដែរ៕ *ដោយ ឆ.ឆ*

# សន្តក្លេម៉ាំង



លោកក្លេម៉ាំង កើតនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី នាពាក់កណ្ដាលស.វ ទី១ ដែលមានគ្រួសារ ជាអ្នកមានទ្រព្យ។ យុវជនក្លេម៉ាំង រៀនអក្សរសិល្ប៍ រៀនទស្សនវិជ្ជា ច្បាប់ ភាសាក្រិក និង ភាសាហេប្រឺ។ គាត់គោរពថ្វាយបង្គំព្រះផ្សេងៗ ដូចជនជាតិរ៉ូម៉ាំងទាំងអស់នាសម័យនោះ។ ថ្ងៃមួយមិត្តភក្តិរបស់គាត់ម្នាក់ជាគ្រីស្តបរិស័ទ បានហៅគាត់ឲ្យចូលរួមអធិដ្ឋានជាមួយគ្នា។ លោកសិលានិយាយអំពីព្រះយេស៊ូ ដែលបានបូជាព្រះជន្ម និងមានជីវិតថ្មីដែលធ្វើឲ្យក្លេម៉ាំងរំភើបចិត្ត។ ក្រោយមកលោកបានមករៀនអប់រំជំនឿ និងទទួលពិធីជ្រមុជទឹកជាគ្រីស្តបរិស័ទនារាត្រីបុណ្យចម្លង។

លោកក្លេម៉ាំង ផ្លាស់ប្ដូររបៀបរស់នៅ គឺគាត់ប្រគល់ ទ្រព្យសម្បត្តិទាំងអស់របស់គាត់ឲ្យព្រះសហគមន៍ សម្រាប់ជួយអ្នកក្រីក្រ។ ក្រោយមក គាត់ថ្វាយខ្លួន ដោយឲ្យលោកសិលាដាក់ដៃលើតែងតាំងគាត់ ឲ្យជួយណែនាំព្រះសហគមន៍។ ថ្ងៃមួយលោកបានជួបជាមួយលោក ប៉ូល ហើយធ្វើដំណើរទៅជាមួយគាត់។ ក្លេម៉ាំងបានធ្វើឲ្យមនុស្សរួមដំណើរជាមួយ ចង់ក្លាយជាគ្រីស្តបរិស័ទ។

នៅសម័យនោះ ព្រះចៅអធិរាជរ៉ូម៉ាំង ធ្វើទុក្ខបុកម្នេញ និងស្អប់គ្រីស្តបរិស័ទយ៉ាងខ្លាំង ត្បិតពួកគេគោរពថ្វាយបង្គំតែព្រះយេស៊ូ។ លោកសិលា និងលោកប៉ូលត្រូវគេសម្លាប់។ លោកក្លេម៉ាំងត្រូវបានគ្រីស្តបរិស័ទសូមលោកធ្វើជាអភិបាលក្រុងរ៉ូម (សម្ដេចប៉ាប) ណែនាំពួកគេបន្ត។ គាត់មានតួនាទី២ គឺពង្រឹងជំនឿរបស់គ្រីស្តបរិស័ទ និងធ្វើឲ្យគេរួមគ្នាជាធ្លុងតែមួយ។

ថ្ងៃមួយ គេចាប់លោកទៅតុលាការ ដើម្បីកាត់ក្ដី តែដោយលោកមានចិត្តស្មោះត្រង់ចំពោះព្រះយេស៊ូ គេបញ្ជូនគាត់ទៅប្រទេសរុស្ស៊ី ជាមួយគ្រីស្តបរិស័ទជាច្រើន។ នៅទីនោះ ជនជាតិរ៉ូម៉ាំង បង្ខំគ្រីស្តបរិស័ទ និងលោកឲ្យធ្វើពលកម្មយ៉ាងសែនវេទនា តែលោកនៅតែលើកទឹកចិត្តដល់ពួកគេ។ ព្រះជាម្ចាស់ បានធ្វើការអស្ចារ្យ ដោយឲ្យមានទឹកផុសចេញពីដី នៅពេលលោកកំពុងអធិដ្ឋាន។ អ្នកទោសជាច្រើនប្រែចិត្តគំនិត និងទទួលអគ្គសញ្ញាជ្រមុជទឹកពីលោក ធ្វើឲ្យលោកកាន់តែមានឈ្មោះល្បី។ ក្រោយមក ព្រះចៅអធិរាជ បានឲ្យគេសម្លាប់លោក ដោយប្រានទម្លាក់ពីលើប្រាំងសមុទ្រ៕

# តួនាទីគណៈកម្មការតុលាការវិនិច្ឆ័យមរណសាក្សីនៅកម្ពុជា



លោកបូជាចារ្យ ធ័ត្រសិរី សាកសួរសាក្សី លោកម៉ប ប៊ុណ្ណារាយ ក្នុងអង្គតុលាការ។ រូបថតៈ សុធីរិទ្ធ

ព្រះសហគមន៍កាតូលិកកម្ពុជា បានរៀបចំឲ្យមាន ការស៊ើបអង្កេតជាផ្លូវការអំពីមរណសាក្សីនៅកម្ពុជា កាលពីថ្ងៃទី១ ឧសភា២០១៥កន្លងទៅ នៅភូមិតាំងគោកខេត្តកំពង់ធំ។ បេក្ខភាពជាមរណសាក្សីទាំងនោះ មានចំនួន ៣៥ នាក់ ដែលមានឋានៈពីលោកអភិបាល រហូតដល់គ្រហស្ថ ហើយពួកគាត់ទាំងនោះបានបាត់បង់ជីវិត ចាប់ពីសង្គ្រាមផ្ទុះឡើងនៅឆ្នាំ១៩៧០ រហូតដល់សម័យប៉ុលពតក្នុងឆ្នាំ១៩៧៧។ បុគ្គលដែលត្រូវបានគេស្នើសុំទៅជាមរណសាក្សី ក្នុងដំណាក់កាលនេះហៅថា "អ្នកបម្រើរបស់ព្រះជាម្ចាស់"។ ដើម្បីបន្តការស៊ើបអង្កេតច្បាប់ក្រសួង តែងតាំងអ្នកមានសុភមង្គល និងសន្តបុគ្គលតម្រូវឲ្យបង្កើតអង្គតុលាការស៊ើបអង្កេតភូមិភាគ( Diocesan Inquiry) ដែលមានសមាជិកចំនួន៤នាក់ មានដូចជា ចៅក្រម អ្នកគាំទ្រសេចក្តីយុត្តិធម៌ សារការី សារការីជំនួយ ដើម្បីជួយអង្គតុលាការស៊ើបអង្កេតនេះ ជាពិសេសចៅក្រម អាចកាត់ក្តីយ៉ាងត្រឹមត្រូវ។ យើងត្រូវការគណៈកម្មការចំនួន ២ គឺគណៈកម្មការប្រវត្តិសាស្ត្រ និង គណៈកម្មការទេវវិទ្យា ដើម្បីជួយចៅក្រមដែលជា លោកអភិបាលអាចវិនិច្ឆ័យករណីថា អ្នកបម្រើរបស់ព្រះជាម្ចាស់នីមួយៗ អាចសមគួរជាសន្តបុគ្គលបានឬទេ។ បច្ចុប្បន្ន អង្គតុលាការស៊ើបអង្កេតនេះកំពុងហៅសាក្សីមក ដើម្បីសាកសួរសេចក្តីពិត។ រាល់មុខងារទាំងអស់នៃគណៈកម្មការ គឺត្រូវតែមានការតែងតាំង ឬអនុម័តដោយលោកអភិបាល។

លោកបូជាចារ្យរឿង ធ័ត្រសិរី ជាអគ្គអធិការបតី លោកអភិបាលភូមិភាគភ្នំពេញ និងជាអ្នករៀបចំសំណុំឯកសារនៃមរណសាក្សី បានមានប្រសាសន៍ទៀតថា មុនពេលបង្កើតតុលាការនេះបាន គឺមុនដំបូងត្រូវមានអ្នកស្នើសុំសិន គឺជាអ្នកដែលមានបំណង ចង់ឲ្យមានការប្រកាសជាផ្លូវការ ជាមរណសាក្សីដែលយើងអាចហៅបានថា ដើមចោទ (តាមប្រព័ន្ធតុលាការ)។ហើយសម្រាប់ករណីរបស់យើងនេះ អ្នកស្នើសុំនោះគឺជាក្រុមសាសនទូតពីទីក្រុងប៉ារីស បានតែងតាំង ឲ្យមានអ្នករៀបចំសំណុំឯកសារ (Postolator) គឺជាអ្នកដែលរៀបចំសំណុំរឿងទាំងអស់ តាមប្រព័ន្ធតុលាការ។ គឺជាអ្នកធ្វើពាក្យសុំអ្វីៗទាំងអស់ត្រឹមត្រូវតាមផ្លូវច្បាប់។ ដូច្នេះអ្នកស្នើសុំ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាធររបស់ភូមិភាគរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ដែលស្លាប់នៅក្នុងភូមិភាគនោះ ដែលសព្វថ្ងៃ យើងមានទាំងបីភូមិភាគ ដូច្នេះដើម្បីក្លាយទៅជា ករណីមរណសាក្សីតែមួយ លោកអភិបាលពីភូមិភាគ បាត់ដំបង និងភូមិភាគកំពង់ចាមបានប្រគល់សិទ្ធិស៊ើប អង្កេតនេះ ឲ្យលោកអភិបាលភូមិភាគ ភ្នំពេញទាំងអស់ ដើម្បីធ្វើជាលោកអភិបាលអធិបតី ក្នុងអង្គតុលាការនេះ លោកអភិបាលមានសិទ្ធិអំណាចបី គឺ និតិបញ្ញាត (អ្នកចេញច្បាប់) និតិប្រតិបត្តិ (អ្នកអនុវត្តច្បាប់) និង តុលាការ (អ្នកសម្រេចសេចក្តី)។

លោកបូជាចារ្យពន្យល់ទៀតថា អំពីតួនាទីរបស់អង្គតុលាការវិនិច្ឆ័យ មរណសាក្សីនៅកម្ពុជានេះមានដូចជា៖

- តួនាទីរបស់លោកអភិបាល អធិបតី៖ គឺត្រូវតាមដាន និងត្រួតពិនិត្យរាល់សំណុំឯកសារទាំងអស់ ទាំងខាងអ្នករៀបចំសំណុំឯកសារ (Postulator) ទាំងខាងគណៈកម្មការតុលាការស៊ើបអង្កេត ដែលបានសាកសួរក្តីមកពីសាក្សី និងខាងគណៈកម្មការ២ទៀត គឺគណៈកម្មការប្រវត្តិសាស្ត្រ និង គណៈកម្មការទេវវិទ្យា។ បន្ទាប់ពីពិនិត្យ និងសង្កេតអំពីរបាយការណ៍នីមួយៗ នៃគណៈកម្មការទាំងអស់សព្វគ្រប់ លោកអភិបាល នឹងធ្វើសេចក្តីសម្រេចថានរណាខ្លះក្នុងចំណោម៣៥នាក់នេះ នឹងត្រូវបញ្ជូនសំណុំឯកសារ បន្តទៅកាន់សន្តអាសនៈ ដើម្បីពិនិត្យសម្រេច និងប្រកាសជាផ្លូវការថាជាមរណសាក្សី។

- តួនាទីអ្នករៀបចំសំណុំឯកសារ (Postulator)៖ គឺប្រៀបដូចជា មេធាវីនៃដើមបណ្តឹងដូច្នេះដែរ គឺគាត់មានតួនាទី ប្រមូលយកឯកសារទាំងអស់ ដែលមានអំពីអ្នកបម្រើព្រះជាម្ចាស់ដែលត្រូវស្នើសុំជាមរណសាក្សី និងស្វែងរកអ្នកផ្តល់សក្ខីកម្មផ្សេងៗ អំពីអ្នកបម្រើព្រះជាម្ចាស់ទាំងនោះ ដើម្បីដាក់បញ្ជូនទៅកាន់អង្គតុលាការស៊ើបអង្កេត ដែលមានលោកអភិបាលជាអធិបតី។ លោកអភិបាលក្នុងឋានៈជាចៅក្រមត្រូវពិនិត្យមើលសំណុំរឿងដែលបានស្នើសុំនោះ។ ដោយយោងតាមសេចក្តីស្នើសុំ លោកអភិបាលអធិបតី នឹងសុំអនុញ្ញាតពីសន្តអាសនៈថា គ្មានឧបសគ្គក្នុងការបន្ត ( Nihil Obstat )ទន្ទឹមគ្នា លោកក៏បើកការស៊ើបអង្កេត។

- តួនាទីអ្នកគាំទ្រ សេចក្តីយុត្តិធម៌ (Promoter of Justice)៖ ជាអ្នកដែលចេញក្រិត្យមួយ ដើម្បី កោះហៅសាក្សីរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់មកសួរនាំនៅក្នុងអង្គតុលាការ អំពីប្រវត្តិការរស់នៅ របៀបបង្ហាញជំនឿ ជាពិសេសគឺនៅពេលចុងក្រោយ នៃជីវិតរបស់ពួកគាត់។ ដូច្នេះអ្នកគាំទ្រសេចក្តីយុត្តិធម៌ នឹងរៀបចំជាសំណួរ ដើម្បីសួរសាក្សីទាំងនោះ។ ជាមួយគ្នានេះដែរ គាត់ក៏ត្រូវមើលសំណុំរឿងរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ ដែលបញ្ជូនដោយអ្នករៀបចំសំណុំឯកសារផងដែរ គឺទាក់ទងនឹងឯកសារសរសេរ អំពីភាពដ៏វិសុទ្ធរបស់ពួកគាត់។

- តួនាទីសារការី (Notary) ជាអ្នកធានារ៉ាប់រងឯកសារ ដែលមាននៅក្នុងអង្គតុលាការទាំងអស់ គឺមានឯកសារស្នើសុំឯកសាសំភាសន៍ ដែលបានស្រាវជ្រាវមកដែលទាក់ទងនឹងករណីផ្សេងៗរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ ។ គ្រប់ឯកសារ ដែលប្រមូលបានទាំងអស់ ត្រូវតែមានចុះហត្ថលេខាគ្រប់ទំព័រទាំងអស់ទទួលស្គាល់ ដោយសារការីផ្ទាល់។ បើឯកសារណាអត់មានហត្ថលេខារបស់សារការីទេចាត់ទុកជាអសារបង់។ សារការីត្រូវមានវត្តមានដាច់ខាតនៅក្នុងអង្គតុលាការ។ នៅក្នុងពេលសាកសួរសាក្សី សារការីត្រូវកត់ត្រារាល់ចម្លើយទាំងអស់របស់សាក្សី ដែលឆ្លើយនៅក្នុងអង្គតុលាការ។ ក្រោយមកឯកសារទាំងអស់ ដែលមានសារការីត្រូវរក្សាទុកដោយត្រឹមត្រូវ និងទុកជាការសម្ងាត់ រហូតដល់ថ្ងៃដែលប្រកាសជាផ្លូវការណ៍ពីសន្តអាសនៈនៃទីក្រុងរ៉ូម។

- តួនាទីសារការីជំនួយ (Notary Assistant) មានតួនាទីជួយសម្រួលដល់ការងាររបស់សារការីក្នុងដំណើរការនៅក្នុងអង្គតុលាការទាំងមូល៕



*លោកបូជាចារ្យ ផាន បូរី*

**៦ កញ្ញា ៖ (អាទិត្យទី២៣ ក្នុងរដូវធម្មតា) មក ៧,៣១-៣៧**

គោលបំណងរបស់មនុស្សគថ្លង់ គឺចង់ឱ្យព្រះយេស៊ូ ប្រោសគាត់ឱ្យបានស្ដាប់ឮនិងនិយាយបានដូចគេដូចឯង។ ភ្លាមនោះឃើញថា ព្រះយេស៊ូព្រះ សណ្ដាប់ពាក្យអង្វររបស់គាត់ ដោយព្រះអង្គយល់ដល់ជំនឿ ដែលគាត់ទុកចិត្ត លើព្រះអង្គ ដោយសារជំនឿ នាំឲ្យគាត់បានសង្គ្រោះ។ គឺ ព្រះអង្គនឹងហើយជាព្រះគ្រីស្ដ ព្រះអង្គ នាំឱ្យអស់អ្នកដែលសង្គមមិនរាប់រក មិនអើពើជាមួយឲ្យបានចូលក្នុងសង្គមបានដូចគេដូចឯង ។

ម្យ៉ាងវិញទៀត ព្រះយេស៊ូធ្វើឱ្យព្រះបន្ទូលសន្យាក្លាយជារូបរាង គឺការសង្គ្រោះបានចូលក្នុងសង្គមមនុស្ស ដោយសេចក្ដីស្រឡាញ់ មេត្តាករុណា។ ព្រះជាម្ចាស់នាំឱ្យអ្នកបាបមានទំនាក់ទំនង ជាមួយព្រះអង្គ ។

មានពេលខ្លះ យើងក៏ដូចមនុស្សគថ្លង់យ៉ាងនោះដែរ។ ពេលខ្លះ យើងមិនចេះស្ដាប់ព្រះបន្ទូលព្រះអង្គ មិនចេះនិយាយអំពីព្រះអង្គ លើសពីនោះទៅទៀត មិនហ៊ានប្រកាសថា ខ្លួនជាគ្រីស្ដបរិស័ទទេ ខ្លាចខ្មាសគេ ខ្លាចបាត់បង់កិត្តិយស ដោយសារតែព្រះនាមព្រះយេស៊ូ ។

ហេតុនេះ ចូរយើងនាំគ្នា សុំទោសព្រះអង្គ អង្វរព្រះអង្គ សូមព្រះអង្គ បើកត្រចៀក បើកដួងចិត្តដ៏រឹងរូសដើម្បីឱ្យជីវិតមានរសជាតិ មានកំលាំង មានសេចក្ដីក្លាហាន ហើយទូលអង្វរព្រះជាម្ចាស់ជាមួយគ្នាថា៖ "ឱ!ព្រះអម្ចាស់អើយ សូមព្រះអង្គបើកត្រចៀក ពាល់អណ្ដាតទូលបង្គំ ឱ្យចេះថ្លែងព្រះបន្ទូលព្រះអង្គដោយសមរម្យ"។

**១៣ កញ្ញា៖ (អាទិត្យទី២៤ ក្នុងរដូវធម្មតា) មក ៨,២៧-៣៥**

ព្រះបន្ទូលនេះ ជួយរម្លឹកយើងថា តើព្រះអង្គជានរណា?

តាមគំនិតរបស់លោកសិលា គឺព្រះអង្គជាស្ដេច តាមរបៀបលោកកិយ មានអំណាច មានទ្រព្យសម្បត្តិ មានទាហានរាប់ពាន់នាក់។ ជាស្ដេចដែលគេកំពុងតែរង់ចាំ ដើម្បីរំដោះពួកគេឱ្យរួចពីការជិះជាន់ពីសំណាក់ពួកបរទេស។

ផ្ទុយទៅវិញ ព្រះយេស៊ូ ប្រាប់ក្រុមសាវកថា ព្រះអង្គត្រូវរងទុក្ខលំបាកសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។ គំនិតរបស់លោកសិលា នៅតែមិនយល់ ព្រមទាំងបន្ទោសព្រះអង្គថែមទៀតផង ព្រោះលោកសិលាស្រឡាញ់ព្រះយេស៊ូតាមរបៀបមនុស្ស ឬតាមរបៀបលោកកិយ ផ្ទុយទៅវិញ ព្រះអង្គមិនធ្វើតាមគំនិតលោកិយទេ គឺតាមព្រះបំណងព្រះបិតាវិញ។ សម្រាប់គ្រីស្ដបរិស័ទ តើព្រះអង្គជានរណា? តើធ្វើដូចម្ដេច ដើម្បីស្គាល់ព្រះអង្គ? តើយើងមានទំនាក់ទំនងយ៉ាងណាជាមួយព្រះអង្គ?

សូមគិតថា ព្រះអង្គជាមិត្តសម្លាញ់របស់មនុស្សគ្រប់រូប ហើយទទួលស្គាល់ថា ព្រះអង្គជាព្រះគ្រីស្ដជាព្រះសង្គ្រោះ។ ព្រះអង្គនាំយើងទៅកាន់ព្រះបិតា។ យើងត្រូវបង្ហាញ សកម្មភាពរបស់យើងដោយធម៌មេត្តាករុណា ជួយដល់អ្នកក្រីក្រ ប្រកាសជំនឿរបស់ខ្លួន ដល់មនុស្សគ្រប់ជាតិសាសន៍ ជាពិសេសប្រជាជនខ្មែរ ថា មនុស្សម្នាក់ៗសុទ្ធតែមានតម្លៃស្មើៗគ្នា។ ចូរអធិដ្ឋាន ចូលរួមអភិបូជា និងយកព្រះបន្ទូលព្រះអង្គជាអាវុធ និងជាអាហារដើម្បីចិញ្ចឹមជីវិតខាងវិញ្ញាណ។

**២០ កញ្ញា ៖ (អាទិត្យទី ២៥ក្នុងរដូវធម្មតា) មក៩,៣០-៣៧**

សភាវៈរបស់មនុស្ស គឺចង់មានមុខមាត់ ចង់បានអំណាច ចង់ឱ្យអ្នកដទៃគោរពថាខ្លួនអស្ចារ្យ តែព្រះយេស៊ូ ចូលចិត្តបន្ទាបខ្លួន ចូលចិត្តទាក់ទងជាមួយអ្នកតូចតាច គឺអ្នកដែលគ្មាននរណារាប់រក។ ព្រះអង្គធ្វើដូច្នេះ ដោយមានបំណងបញ្ជាក់ឲ្យគេដឹងថា មនុស្សគ្រប់រូបមានតម្លៃដ៏ប្រសើរថ្លៃថ្លា មនុស្សគ្រប់ៗរូបសុទ្ធតែជាបុត្រធីតារបស់ព្រះជាម្ចាស់ ។

សន្តវ៉ាំងសង់ដឺប៉ូល ជាបូជាចារ្យដ៏មានឈ្មោះល្បីល្បាញ ខាងបង្ហាញធម៌មេត្តាករុណា ស្រឡាញ់អ្នកក្រីក្រ និងធ្វើទានជួយអ្នកក្រីក្រ ក៏ដោយសារព្រះបន្ទូលព្រះយេស៊ូ ជ្រាប ចូលក្នុងជីវិត របស់គាត់ ព្រមទាំងធ្វើឱ្យគាត់មានកំលាំងរស់នៅជាមួយអស់អ្នកដែលអស់សង្ឃឹម អ្នកគ្មានទីពឹង។ល។

សន្ត សន្តី ជាគំរូដែលនាំឱ្យអ្នកជឿចេះបំរើ មិនគ្រាន់តែមើលពីចំងាយ ធ្វើសើៗនោះទេ ផ្ទុយទៅវិញធ្វើយ៉ាងអស់ពីចិត្តគំនិត អស់ពីស្មារតី។ ជួយគេដោយមិនខ្លាចពីការនឿយហត់ ឬខាតបង់ពេលវេលា។

យើងជាគ្រីស្ដបរិស័ទក៏ដូចក្រុមគ្រីស្ទូតពីសម័យដើមដែរ គឺចង់មានកិត្តិយស និងអំណាច តែព្រះយេស៊ូបានប្រៀនប្រដៅយើងថា អ្នកធំជាងគេគឺអ្នកបម្រើអ្នកដទៃ ជាពិសេសអ្នកតូចតាច និងអ្នកក្រីក្រ ។

ហេតុនេះហើយ "បើអ្នកណាចង់ធ្វើមេគេ អ្នកនោះត្រូវដាក់ខ្លួនឱ្យតូចជាងគេ ព្រមទាំងបម្រើគេទាំងអស់គ្នាផង"

**២៧ កញ្ញា ៖ (អាទិត្យទី ២៦ក្នុងរដូវធម្មតា) មក៩,៣៨-៤៣.៤៥.៤៧-៤៨**

ព្រះយេស៊ូមានបំណងឱ្យមនុស្សទាំងអស់ប្រព្រឹត្តអំពើល្អ ទោះបីសាសនាណាក៏ដោយ ព្រះអង្គមិនរើសមុខនណាមួយឡើយ អ្នកមាន អ្នកក្រ អ្នកខ្ពិនខ្ពាក់ សខ្មៅ មនុស្សទាំងអស់សុទ្ធតែមានតម្លៃស្មើៗគ្នា ។

ម្យ៉ាងវិញទៀត នៅពេលយើងស្គាល់នណាម្នាក់ច្បាស់លាស់ នាំឱ្យយើងងាយស្រួលទុកចិត្តលើគេ គឺស្រ្តបរិស័ទក៏ដូចគ្នាដែរ ពេលណាស្ដាប់ព្រះបន្ទូលព្រះយេស៊ូកាន់តែច្រើន កាន់តែទុកចិត្តលើព្រះអង្គ ព្រមទាំងមានភាពស្និទ្ធស្នាលជាមួយព្រះអង្គកានតែប្រសើរដែរ។ ជាពិសេសការអធិដ្ឋានដោយប្រើព្រះបន្ទូលនាំឱ្យយើងជួបព្រះយេស៊ូដោយផ្ទាល់ ព្រមទាំងដឹងអ្វីដែលល្អ និងអ្វីដែលអាក្រក់។ គឺនាំឱ្យយើងចេះថ្លឹងថ្លែង តាមរបៀបត្រឹមត្រូវ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "ប្រសិនបើដៃរបស់អ្នក នាំឱ្យអ្នកប្រព្រឹត្តអំពើអាក្រក់ ចូរកាត់វាចេញ" ស្ដាប់ទៅហាក់បីដូចជាមានន័យខ្លាំង តែនាំឱ្យអស់អ្នកដែលចេះតែប្រព្រឹត្តអំពើអាក្រក់អាចកែប្រែខ្លួនបាន អស់អ្នកដែលមានចិត្តគំនិតធ្វើអ្វីដែលល្អខិតខំបន្ត ទៅមុខទៀតដោយសេចក្ដីល្អ ។

ព្រះយេស៊ូចង់ប្រៀនប្រដៅយើងថា ត្រូវស្រឡាញ់គ្រីស្ដបរិស័ទ និកាយផ្សេង ៗ ព្រោះគេក៏ជឿលើព្រះយេស៊ូដូចយើងដែរ ត្រូវខិតខំអធិដ្ឋាន ឱ្យយើងចេះរួបរួមគ្នាជាធ្លុងតែមួយ ឱ្យក្លាយជាបងប្អូនយ៉ាងពិតប្រាកដ ដោយសារយើងមានព្រះបិតាតែមួយ។ រួមគ្នាបង្ហាញធម៌មេត្តាករុណាដល់អ្នកតូចតាច ផ្ដល់តម្លៃដល់គេ ព្រោះមនុស្សទាំងអស់សុទ្ធតែមានតម្លៃ ។

ហេតុនេះ ពេលណាយើងស្គាល់ទុក្ខព្រួយរបស់នណាម្នាក់ យើងអាចជួយគេទាំងកំលាំងកាយ ទាំងការអធិដ្ឋាន ៕

## កំណាព្យ យើងត្រូវមានចិត្តមេត្តាករុណា

( បទព្រហ្មគិត )



*និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និងសុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្នូល / JSC*

១ - មានរូបកាយជីវិត
មានក្រទ្រព្យធនធាន
មានគំនិតប្រាជ្ញាញាណ
ចិត្តជាស្ពានទានករុណា ។

២ - ចេះជួយនិងអាណិត
សាងល្អក្នុងចិន្តា
សន្ដោសពិតកុំមុសា
ត្រូវមេត្តាចិត្តប្រណី ។

៣ - អត់ឱនដល់ផងគ្នា
រក្សាចិត្តខន្តី
កុំចងពារទោះប្រុសស្រី
សាងដើម្បីផ្លូវជីវិត ។

៤ - ផ្លូវល្អកើតមង្គល
ស៊ូសាងភាពជាមិត្ត
និងមានដល់សេរីពិត
កុំចងចិត្តជាសត្រូវ ។

៥ - អស់នេះមិនមែនគាប់
បង្កើតក្ដីហ្មងសៅ
ព្រោះគ្មានភ័ព្វរហូតទៅ
ភាពល្ងង់ខ្លៅដាក់ខ្លួនឯង ។

៦ - លបលួចមានបំណង
អំនួតអួតអង្វែង
ហិង្សាប៉ងឥតខ្លាចក្រែង
ឫកសម្ដែងអាងអំណាច ។

៧ - ជាមនុស្សគ្រប់រូបា
ភាពពិតរិទ្ធអំណាច
ចូររក្សាកុំកោងកាច
នោះមិនអាចប្រសើរឡើយ ។

៨ - តូចទាបរាបទន់ភ្លន់
ករុណាមេត្តាហើយ
ខ្ពស់លើសលន់កុំកន្តើយ
ចិត្តជាត្រើយសន្ដោសគ្នា ។

៩ - មានធម៌សប្បុរស
សាងល្អចំពោះគ្នា
កុំសាងទោសរាល់វេលា
ជោគជ័យាគ្រាថ្ងៃមុខ ។

១០-ព្រះតែងប្រទានពរ
ផុតភ័យក្ដីកាយទុក្ខ
ឲ្យមនុស្សល្អជួបក្ដីសុខ
ជួបតែសុខជរាបអើយ ៕

# វិទ្យាស្ថានសន្តប៉ូល



## ថ្នាក់បរិញ្ញាបត្រ

វិស្វកម្មកម្មវិធី (Software Engineering)

- មហាវិទ្យាល័យព័ត៌មានវិទ្យា Faculty of Information Technology
  - វិស្វកម្មកម្មវិធី ( Software Engineering )
  - ទូរគមនាគមន៍ និងបណ្ដាញ ( Telecommunication and Network )
- ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស Department of English Literature
  - អប់រំភាសាអង់គ្លេស ( Teaching English as Foreign Language)
  - ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង ( English for Communication)
- ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍ Department of Tourism Management
- ដេប៉ាតឺម៉ង់កសិកសាស្ត្រ Department of Agronomy
- ដេប៉ាតឺម៉ង់សង្គមកិច្ច Department of Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ Software Development
- គ្រប់គ្រងប្រព័ន្ធ និងបណ្ដាញកុំព្យូទ័រ System and Network Administration
- បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ Teaching English As Second Language
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច Hotel and Hospitality
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ Fruit and Vegetable Crop Production
- ជំនាញកែច្នៃអាហារ Food Processing
- ប្រព័ន្ធកសិកម្មចម្រុះ Integrated Farming System
- ពេទ្យសត្វ Veterinary
- ថែទាំកុមារ Child care

## លក្ខខណ្ឌចូលរៀន

**សម្គាល់ ៖** រៀនបន្ថែម២ឆ្នាំនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រ

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើសម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២. បេក្ខជនធ្លាក់ថ្នាក់ទី១២ អាចចូលរៀនថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

ចាប់ផ្ដើមលក់ពាក្យ និងទទួលពាក្យ

* ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៥

* ចូលរៀនឆមាសទី១ ខែវិច្ឆកា ឆ្នាំ២០១៥

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002 / 032 639 0003 Email: spi.takeo@gmail.com | Web: www.spi.edu.kh


# សេចក្ដីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ធ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្ដល់ព័ត៌មានបន្ថែមអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរ វត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្ដល់ឈ្មោះអ្នកដែលអាចផ្ដល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម


Tel : 077 800 211 / 096 34 22 144

ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

Email: martyrscambodia@gmail.com